## ឯកកៈ ពួកធម៌មួយ

១-បមាទ សេចក្តីប្រមាទ ជាកំពូលនៃអកុសលធម៌ទាំងពួង ។

១-អប្បមាទ សេចក្តីមិនប្រមាទ ជាកំពូលនៃកុសលធម៌ទាំងពួង។

១-មិច្ឆាទិដ្ឋិ សេចក្តីយល់ឃើញខុស ។

១-សម្មាទិដ្ឋិ សេចក្តីយល់ឃើញត្រូវ ។

១-សព្វេ សត្តា អាហារដ្ឋិតិកា សត្វទាំងអស់រស់នៅបានដោយអាស្រ័យអាហារ ។

## ទុកៈ ពួកធម៌ពីរ ធម៌ ២ យ៉ាង

១-សង្ខតធម៌ ធម៌ដែលបច្ច័យប្រជុំតាក់តែងបាន ។

២-អសង្ខតធម៌ ធម៌ដែលបច្ច័យប្រជុំតាក់តែងមិនបាន ។

## សង្ឃ ២ ពួក

១-សម្មតិសង្ឃ បានដល់ភិក្ខុបុថុជ្ជនតាំងពិចំនួនរូបឡើងទៅ ។

២-អរិយសង្ឃ បានដល់ព្រះអរិយសាវកទាំងគូ ។

## មនុស្សអស្ចារ្យ ២ ពួក

១-ព្រះសម្មាសម្ពុទ្ធ

២-ស្តេចចក្រពត្តិ

## ភូមិរបស់សប្បុរស ២ យ៉ាង

១-កតញ្ញូ អ្នកដឹងឧបការគុណដែលគេធ្វើចំពោះខ្លួន ។

២-កតវេទី អ្នកធ្វើឧបការតបគេវិញ ។

## បរិស័ទ ២ យ៉ាង

១-ឧក្កាចិតបរិសា បរិស័ទរបកាន់ពួក ។

២-សមគ្គាបរិសា បរិស័ទព្រមព្រៀងគ្នា ។

## ទោសគួរវៀរ ២ យ៉ាង

១-ទិដ្ឋធម្មិកវជ្ជ ទោសក្នុងបច្ចុប្បន្ន ។

២-សម្បរាយិកវជ្ជ ទោសក្នុងបរលោក ។

## ធម៌ខ្មៅ ២ យ៉ាង

១-អហិរិក មិនខ្មាស់បាប ។

២-អនោត្តប្ប មិនរអែងខ្លាចបាប ។

## ធម៌ស ២ យ៉ាង

១-ហិរិ ខ្មាស់បាប ។

២-ឱត្តប្ប រអែងខ្លាចបាប ។

(ធម៌ស ២ យ៉ាងនេះ ហៅថា លោកធម៌ក៏បាន)

## កន្លែងសម្រាប់ទទួលមនុស្សទ្រុស្តសីល ២ យ៉ាង

១-និរយ នរក ។

២-តិរច្ឆានយោនិ កំណើតតិរច្ឆាន ។

## កន្លែងសម្រាប់ទទួលមនុស្សមានសីល ២ យ៉ាង

១-ទេវ ស្ថានទេវតា ។

២-មនុស្ស ស្ថានមនុស្ស ។

**សេចក្ដីសុខ ២ យ៉ាង**

១-គិហិសុខ សេចក្ដីសុខរបស់គ្រហស្ថ ។

២-បព្វជ្ជាសុខ សេចក្ដីសុខក្នុងផ្នួស ។

**សេចក្ដីសុខ ២ យ៉ាងទៀត**

១-កាមសុខ សេចក្ដីសុខក្នុងកាម ។

២-នេក្ខម្មសុខ សេចក្ដីសុខក្នុងការចេញចាកកាម ។

**សេចក្ដីសុខ ២ យ៉ាងទៀត**

១-សាសវសុខ សេចក្ដីសុខប្រកបដោយអាសវៈ ។

២-អនាសវសុខ សេចក្ដីសុខឥតអាសវៈ ។

**សេចក្ដីសុខ ២ យ៉ាងទៀត**

១-កាយិកសុខ សេចក្ដីសុខកាយ ។

២-ចេតសិកសុខ សេចក្ដីសុខចិត្ត ។

**បុគ្គលរកបានដោយក្រ ២ ពួក**

១-បុព្វការី បុគ្គលអ្នកធ្វើឧបការៈមុន ។

២-កតញ្ញូកតវេទី បុគ្គលអ្នកដឹងឧបការៈ ដែលគេធ្វើហើយធ្វើ

ធ្វើតបឧបការៈគេវិញ ។

**បច្ច័យនាំអោយកើតរាគៈ ២ យ៉ាង**

១-សុភនិមិត្ត កំណត់នូវអារម្មណ៍ថាល្អ ។

២-អយោនិសោមនសិការ មិនធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ។

**បច្ច័យនាំអោយកើតទោសៈ ២ យ៉ាង**

១-បដិឃនិមិត្ត កំណត់ទុកនូវសេចក្ដីថ្នាំងថ្នាក់ ។

២-អយោនិសោមនសិការ មិនធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ។

**ទាន ២ យ៉ាង**

១-អាមិសទាន អោយអាមិស ។

២-ធម្មទាន អោយធម៌ ។

**ចាគៈ ២ យ៉ាង**

១-អាមិសច្ចាគ លះអាមិស ។

២-ធម្មច្ចាគ លះធម៌ ។

**សង្គហៈ ២ យ៉ាង**

១-អាមិសសង្គហ សង្គ្រោះដោយអាមិស ។

២-ធម្មសង្គហ សង្គ្រោះដោយធម៌ ។

**បដិសណ្ឋារ ២ យ៉ាង**

១-អាមិសប្បដិសណ្ឋារ ទទួលរាក់ទាក់ដោយអាមិស ។

២-ធម្មប្បដិសណ្ឋារ ទទួលរាក់ទាក់ដោយធម៌ ។

ឯសនា ការស្វែងរក ២ យ៉ាង

១-អាមិសេសនា ការស្វែងរកអាមិស ។

២-ធម្មេសនា ការស្វែងរកធម៌ ។

បូជា ២ យ៉ាង

១-អាមិសបូជា បូជាដោយអាមិស ។

២-ធម្មបូជា បូជាដោយធម៌ ។

សន្និច្ចយ ការសន្សំ ២ យ៉ាង

១-អាមិសសន្និច្ចយ សន្សំអាមិស ។

២-ធម្មសន្និច្ចយ សន្សំធម៌ ។

សន្និច្ចយ ការសន្សំ ២ យ៉ាងទៀត

១-កម្មសន្និច្ចយ សន្សំកម្ម ។

២-បច្ចយសន្និច្ចយ សន្សំបច្ច័យ ។

វិបត្តិ ២ យ៉ាង

១-សីលវិបត្តិ វិបត្តិសីល ។

២-ទិដ្ឋិវិបត្តិ វិបត្តិទិដ្ឋិ ។

សម្បទា ២ យ៉ាង

១-សីលសម្បទា បរិបូរណ៍ដោយសីល ។

២-ទិដ្ឋិសម្បទា បរិបូរណ៍ដោយទិដ្ឋិ ។

បំណងដែលលះបង់បានដោយក្រ ២យ៉ាង

១-លាភាសា បំណងក្នុងលាភ ។

២-ជីវិតាសា បំណងក្នុងជីវិត ។

អន្តរាយ ២ យ៉ាង

១-បាកដបរិស្សយ អន្តរាយប្រាកដ ។

២-បដិច្ឆន្នបរិស្សយ អន្តរាយកំបាំង ។

ផ្លូវឆ្ងាយ ២ យ៉ាង

១-កន្តារទ្ធា ផ្លូវឆ្ងាយគឺកន្តារ(ផ្លូវឆ្ងាយដាច់ស្រយាល) ។

២-វដ្តទ្ធា ផ្លូវឆ្ងាយគឺវដ្តសង្សារ ។

បដិបទា ២ យ៉ាង

១-លាភូបនិសា សេចក្តីប្រតិបត្តិអាស្រ័យលាភ ។

២-និព្វានគាមិនីបដិបទា សេចក្តីរបតិបត្តិ ជាដំណើរទៅកាន់ព្រះនិព្វាន ។

ហេតុនៃសេចក្តីស្រឡាញ់ ២ យ៉ាង

១-បុព្វេសន្និវាសេន ដោយធ្លាប់នៅជាមួយគ្នាក្នុងកាលមុន ។

២-បច្ចុប្បន្នហិតេនវា ដោយធ្វើប្រយោជន៍ក្នុងបច្ចុប្បន្ន ។

បរិឡាហ សេចក្តីក្តៅក្រហាយ ២ យ៉ាង

១-កាយិកបរិឡាហ សេចក្តីក្តៅក្រហាយក្នុងកាយ ។

២-ចេតសិកបរិឡាហ សេចក្តីក្តៅក្រហាយក្នុងចិត្ត ។

### បុគ្គលអ្នកសំឡឹងទោស ២ ពួក

១-រន្ធគវេសក បុគ្គលអ្នកស្វែងរកទោសបំរុងនឹងផ្ចុញផ្ចាល់ ។

២-សកាចសណ្ឋិក បុគ្គលអ្នកស្ថិតនៅក្នុងសភាពចង់ឱ្យចំរើន ។

### សទ្ធា ២ យ៉ាង

១-លោកិយស្សទ្ធា ជំនឿជាលោកិយ (ជំនឿនៅប្រែប្រួល) ។

២-លោកុត្តរស្សទ្ធា ជំនឿជាលោកុត្តរ (ជំនឿឥតប្រែប្រួល) ។

### ហេតុចំរើនអាសវៈ ២ យ៉ាង

១-អធម្មេ ធម្មសញ្ញី សំគាល់ក្នុងអធម៌ ថាជាធម៌ ។

២-ធម្មេ អធម្មសញ្ញី សំគាល់ក្នុងធម៌ ថាជាអធម៌ ។

### សីល ២ យ៉ាង

១-លោកិយសីល សីលជាលោកិយ (សីលរបស់លោកិយជន) ។

២-លោកុត្តរសីល សីលជាលោកុត្តរ (សីលរបស់អរិយបុគ្គល) ។

### បញ្ញា ២ យ៉ាង

១-លោកិយប្បញ្ញា ប្រាជ្ញារបស់លោកិយជន ។

២-លោកុត្តរប្បញ្ញា ប្រាជ្ញារបស់អរិយបុគ្គល ។

### សមាធិ ២ យ៉ាង

១-លោកិយសមាធិ សមាធិរបស់លោកិយជន ។

២-លោកុត្តរសមាធិ សមាធិរបស់អរិយបុគ្គល ។

### ជរា ២ យ៉ាង

១-អប្បដិច្ឆន្នជរា ជរាដែលមិនកំបាំង ។

២-បដិច្ឆន្នជរា ជរាដែលកំបាំង ។

### មរណៈ ៣ យ៉ាង

១-អកាលមរណៈ សេចក្តីស្លាប់ក្នុងសម័យមិនជាកាល ។

២-កាលមរណៈ សេចក្តីស្លាប់ក្នុងសម័យជាកាល ។

### និព្វាន ២ យ៉ាង

១-សឧបាទិសេសនិព្វាន រលត់កិលេសនៅសល់ខន្ធ ។

២-អនុបាទិសេសនិព្វាន រលត់ទាំងកិលេសទាំងខន្ធ ។

## តិកៈ ពួកធម៌បី

### រតនៈ ៣ យ៉ាង

១-ពុទ្ធរតន រតនៈ គឺព្រះពុទ្ធ ។

២-ធម្មរតន រតនៈ គឺព្រះធម៌ ។

៣-សង្ឃរតន រតនៈ គឺព្រះសង្ឃ ។

### ព្រះពុទ្ធ ៣ យ៉ាង

១-សព្វញ្ញូពុទ្ធ ព្រះពុទ្ធដែលទ្រង់ត្រាស់ដឹងហេតុគ្រប់យ៉ាង ។

២-បច្ចេកពុទ្ធ ព្រះពុទ្ធដែលទ្រង់ត្រាស់ដឹងចំពោះខ្លួន ។

៣-អនុពុទ្ធ ព្រះពុទ្ធដែលទ្រង់ត្រាស់ដឹងតាមព្រះសព្វញ្ញុពុទ្ធ(សាវក) ។

## ព្រះធម៌ ៣ យ៉ាង

១-បរិយត្តិធម៌ ធម៌សម្រាប់សិក្សារៀនសូត្របានដល់ព្រះត្រៃបិដក

២-បដិបត្តិធម៌ ធម៌សម្រាប់ប្រតិបត្តិបានដល់ សីល-សមាធិ-បញ្ញា

៣-បដិវេធធម៌ ធម៌ដែលគប្បីត្រាស់ដឹង បានដល់ មគ្គ-ផល ។

## គុណរបស់ព្រះពុទ្ធដោយសង្ខេប ៣ យ៉ាង

១-បញ្ញាគុណ គុណ គឺប្រាជ្ញា ។

២-វិសុទ្ធិគុណ គុណ គឺសេចក្ដីបរិសុទ្ធ ។

៣-ករុណាគុណ គុណ គឺករុណា ។

## សម្បទារបស់ព្រះពុទ្ធមាន ៣ យ៉ាង

១-ហេតុសម្បទា ដល់ព្រមដោយហេតុ ។

២-ផលសម្បទា ដល់ព្រមដោយផល ។

៣-សត្តូបការសម្បទា ដល់ព្រមដោយឧបការដល់សត្វ ។

## ឱវាទរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ ៣ យ៉ាង

១-សព្វបាបស្សអករណំ ទ្រង់ប្រដៅមិនអោយធ្វើបាបគ្រប់យ៉ាង ។

២-កុសលស្សូបសម្បទា ទ្រង់ដៅឱ្យបំពេញការកុសល ។

៣-សចិត្តបរិយោទបនំ ទ្រង់ប្រដៅឱ្យជំរះចិត្តរបស់ខ្លួនឱ្យផូរផង់ ។

## សោតាបន្នបុគ្គល ៣ យ៉ាង

១-ឯកពីជី នៅកើតមួយជាតិទៀត

២-កោលំកោល នៅកើត ២ជាតិខ្លះ, ៣ជាតិខ្លះ,៤ជាតិខ្លះ ៥ជាតិខ្លះ, ៦ជាតិខ្លះ ។

៣-សត្តក្ខត្តុំបរម នៅកើត ៧ ជាតិទៀត ។

## លក្ខណៈរបស់បុគ្គលពាល ៣ យ៉ាង

១-ទុច្ចិន្តិតចិន្តី មានគំនិតគិតអាក្រក់ជាប្រក្រតី ។

២-ទុព្ភាសិតភាសី មានសំដីនិយាយអាក្រក់ជាប្រក្រតី ។

៣-ទុក្កដកម្មការី មានការធ្វើអំពើអាក្រក់ជាប្រក្រតី ។

## លក្ខណៈរបស់បណ្ឌិត ៣ យ៉ាង

១-សុចិន្តិតចិន្តី មានគំនិតល្អជាប្រក្រតី ។

២-សុភាសិតភាសី មានសំដីនិយាយល្អជាប្រក្រតី

៣-សុកតកម្មការី មានការធ្វើអំពើល្អជាប្រក្រតី ។

## បុគ្គល ៣ ពួក

១-គូថភាណី មានសំដីដូចលាមក ។

២-បុប្ផភាណី មានសំដីដូចផ្កា ។

**៣-មច្ឆរាណី** មានសំដីដូចទឹកឃ្មុំ ។

**បុត្រ ៣ ពួក**

**១-អភិជាតបុត្ត** បុត្រដែលអន់ថយជាងមាតាបិតា ។

**២-អនុជាតបុត្ត** បុត្រដែលស្មើគ្នានឹងមាតាបិតា ។

**៣-អតិជាតបុត្ត** បុត្រដែលថ្លៃថ្លាជាងមាតាបិតា ។

**សេចក្តីស្រវឹង ៣ យ៉ាង**

**១-យោព្វនមទ** ស្រវឹងក្នុងវ័យ ។

**២-អារោគ្យមទ** ស្រវឹងក្នុងរូបកាយថា ឥតមានរោគ ។

**៣-ជីវិតមទ** ស្រវឹងក្នុងជីវិត ។

**អធិបតិ ៣ យ៉ាង**

**១-អត្តាធិបតេយ្យ** ប្រារព្ធយកខ្លួនជាធំ ។

**២-លោកាធិបតេយ្យ** ប្រារព្ធយកលោកជាធំ ។

**៣-ធម្មាធិបតេយ្យ** ប្រារព្ធយកធម៌ជាធំ ។

**សប្បុរិសប្បញ្ញត្តិ ៣ យ៉ាង**

**១-ទាន** ការលះទ្រព្យរបស់ខ្លួនដល់អ្នកដែលគួរអោយ ។

**២-បព្វជ្ជា** ការបួសវៀរចាកសេចក្តីអាក្រក់ ។

**៣-មាតាបិតុបដ្ឋាន** ការបំរើមាតាបិតារបស់ខ្លួន ។

**កុសលមូល ៣ យ៉ាង**

**១-អលោភ** មិនជំពាក់ចិត្តក្នុងទ្រព្យរបស់ ។

**២-អទោស** មិនប្រទុស្ត ។

**៣-អមោហ** មិនវង្វេង ។

**អកុសលមូល ៣ យ៉ាង**

**១-លោភ** ជំពាក់ចិត្តក្នុងទ្រព្យរបស់ ។

**២-ទោស** សេចក្តីប្រទុស្ត ។

**៣-មោហ** សេចក្តីវង្វេង ។

**ធម្មជាតិមិនចេះឆ្អែត ៣ យ៉ាង**

**១-សុបិន** ការដេកលក់ ។

**២-សុរាមេរយបាន** ការផឹកសុរានឹងមេរ័យ ។

**៣-មេថុនធម្មសមាបត្តិ** ការសេពមេថុនធម្ម ។

**វិបត្តិ ៣ យ៉ាង**

**១-សីលវិបត្តិ** ខូចសីល គឺទ្រុស្តសីល ។

**២-ចិត្តវិបត្តិ** ខូចចិត្ត គឺគំនិតគិតខុស ។

**៣-ទិដ្ឋិវិបត្តិ** ខូចទិដ្ឋិ គឺសេចក្តីយល់ឃើញខុស ។

**សម្បទា ៣ យ៉ាង**

**១-សីលសម្បទា** ដល់ព្រមដោយសីល ។

**២-ចិត្តសម្បទា** ដល់ព្រមដោយចិត្ត ។

**៣-ទិដ្ឋិសម្បទា** ដល់ព្រមដោយទិដ្ឋិ ។

### សោចេយ្យ ភាពជាបុគ្គលស្អាត ៣ យ៉ាង

**១-កាយសោចេយ្យ** ស្អាតខាងផ្លូវកាយ ។

**២-វចីសោចេយ្យ** ស្អាតខាងផ្លូវវាចា ។

**៣-មនោសោចេយ្យ** ស្អាតខាងផ្លូវចិត្ត ។

### លេខូបម បុគ្គលប្រៀបដោយស្នាមគំនូស ៣ យ៉ាង

**១-បាសាណលេខូបម** បុគ្គលប្រៀបដោយស្នាមគំនូសលើថ្ម ។

**២-បឋវីលេខូបម** បុគ្គលប្រៀបដោយស្នាមគំនូសលើដី ។

**៣-ឧទកលេខូបម** បុគ្គលប្រៀបដោយស្នាមគំនូសលើទឹក ។

### បុគ្គលគួរគប់រក ៣ ពួក

**១-ទុទ្ទទំ ទទាតិ** ឱ្យរបស់ដែលគេឱ្យបានដោយកម្រ ។

**២-ទុក្ករំ ករោតិ** ធ្វើនូវអំពើដែលគេធ្វើបានដោយកម្រ ។

**៣-ទុក្ខមំ ខមតិ** អត់ធន់នូវហេតុដែលគេអត់ធន់បានដោយកម្រ។

### វុឌ្ឍិ សេចក្តីចំរើន ៣ យ៉ាង

**១-សទ្ធាវុឌ្ឍិ** សេចក្តីចំរើនដោយសទ្ធា ។

**២-សីលវុឌ្ឍិ** សេចក្តីចំរើនដោយបញ្ញា ។

**៣-បញ្ញាវុឌ្ឍិ** សេចក្តីចំរើនដោយបញ្ញា ។

### សម្បទា ៣ យ៉ាង

**១-សទ្ធាសម្បទា** ដល់ព្រមដោយសទ្ធា ។

**២-សីលសម្បទា** ដល់ព្រមដោយសីល ។

**៣-បញ្ញាសម្បទា** ដល់ព្រមដោយបញ្ញា ។

### សម្បទា ធម្មជាតិសម្រាប់ធ្វើទានឱ្យមានផល ៣ យ៉ាង

**១-វត្ថុសម្បទា** ដល់ប្រមដោយវត្ថុ គឺទេយ្យវត្ថុដែលកើតឡើងដោយត្រូវធម៌ ។

**២-ចេតនាសម្បទា** ដល់ប្រមដោយចេតនាទាំង៣ គឺៈ បុព្វចេតនា មុញ្ចចេតនា អបរាចេតនា ។

**៣-បូជនីយសម្បទា** ដល់ព្រមដោយបុគ្គលដែលគួរបូជា គឺបដិគ្គាហកអ្នកប្រតិបត្តិល្អ ប្រតិបត្តិត្រឹមត្រូវ ។

### អកុសលវិតក្ក ៣ យ៉ាង

**១-កាមវិតក្ក** សេចក្តីត្រិះរិះក្នុងកាម ។

**២-ព្យាបាទវិតក្ក** សេចក្តីត្រិះរិះក្នុងការព្យាបាទ ។

**៣-វិហឹសាវិតក្ក** សេចក្តីត្រិះរិះក្នុងការបៀតបៀន ។

### កុសលវិតក្ក ៣ យ៉ាង

**១-នេក្ខម្មវិតក្ក** សេចក្តីត្រិះរិះក្នុងការចេញចាកកាម ។

**២-អព្យាបាទវិតក្ក** សេចក្តីត្រិះរិះក្នុងការមិនព្យាបាទ ។

**៣-អវិហឹសាវិតក្ក** សេចក្តីត្រិះរិះក្នុងការមិនបៀតបៀន ។

### ការស្វែងរក ៣ យ៉ាង

១-កាមេសនា ការស្វែងរកកាម ។

២-ភវេសនា ការស្វែងរកភព ។

៣-ព្រហ្មចរិយេសនា ការស្វែងរកព្រហ្មចរិយធម៌ ។

**មានះ ៣ យ៉ាង**

១-សេយ្យោហមស្មិ មានះថាអាត្មាអញប្រសើរជាងគេ ។

២-សទិសោហមស្មិ មានះថាអាត្មាអញស្មើនឹងគេ ។

៣-ហីនោហមស្មិ មានះថាអាត្មាអញអន់ថយជាងគេ ។

**ថេរៈ ៣ ពួក**

១-ជាតិត្ថេរ ជាថេរៈដោយជាតិ គឺមានវស្សាច្រើនអាយុច្រើន ។

២-ធម្មត្ថេរ ជាថេៈដោយធម៌ ។

៣-សម្មតិត្ថេរ ជាថេៈដោយសម្មត ។

**បុគ្គលចាស់ ៣ ពួក**

១-ជាតិវុឌ្ឍ ចាស់ដោយជាតិ (ជាតិក្សត្រ) ។

២-វយវុឌ្ឍ ចាស់ដោយវ័យ (អាយុច្រើន) ។

៣-គុណវុឌ្ឍ ចាស់ដោយគុណ (មានសីលធម៌ច្រើន) ។

**ធម៌ជាគ្រឿងផ្ចាញ់សត្រូវ ៣ យ៉ាង**

១-ឧក្ខាភាវៈ ភាពជាអ្នកឈ្លៀវឆ្លាស់ ។

២-សូរភាវ ភាពជាអ្នកក្លៀវក្លា អង់អាច ។

៣-បញ្ញា ប្រាជ្ញា ។

**អាវុធ ៣ យ៉ាង**

១-សុតាវុធ អាវុធ គឺការស្ដាប់រៀន ។

២-បវិវេកាវុធ អាវុធ គឺការស្ដាប់ ។

៣-បញ្ញាវុធ អាវុធ គឺប្រាជ្ញា ។

**វិវេក សេចក្ដីស្ងាត់ ៣ យ៉ាង**

១-កាយវិវេក ស្ងាត់កាយ (ដោយនៅក្នុងទីស្ងាត់) ។

២-ចិត្តវិវេក ស្ងាត់ចិត្ត (ចាកនីវរណៈ) ។

៣-ឧបធិវិវេក ស្ងាត់ចាកកិលេស ។

**សទ្ធា ៣ យ៉ាង**

១-បសាទសទ្ធា ជំនឿដែលកើតដោយសេចក្ដីជ្រះថ្លា ។

២-ឱកប្បនសទ្ធា ជំនឿដែលតាំងនៅមាំក្នុងវត្ថុដែលគួរជឿ ។

៣-អចលសទ្ធា ជំនឿមិនរំភើបញាប់ញ័រ ។

**លក្ខណៈរបស់អ្នកមានសទ្ធា ៣ យ៉ាង**

១-ទស្សនកាមោសីលវតំ ចង់ជួបចង់ឃើញលោកអ្នកមានសីល ។

២-សទ្ធម្មំសោតុ មិច្ឆតិ ចង់ស្ដាប់ព្រះសទ្ធម្ម ។

៣-វិនេយ្យមច្ឆេរមលំ អាចកំចាត់បង់នូវសេចក្ដី កំណាញ់ជាមន្ទិលបាន។

**សេចក្ដីដឹងប្រមាណ ៣ យ៉ាង**

១-បរិយេសនមត្តា ដឹងប្រមាណក្នុងការស្វែងរក ។

២-បដិគ្គហណមត្តា ដឹងប្រមាណក្នុងការទទួល ។

៣-បរិភោគមត្តា ដឹងប្រមាណក្នុងការបរិភោគ ។

### បុញ្ញកិរិយាវត្ថុ ៣ យ៉ាង

១-ទានមយ បុណ្យសម្រេចដោយការធ្វើទាន ។

២-សីលមយ បុណ្យសម្រេចដោយការរក្សាសីល ។

៣-ភាវនាមយ បុណ្យសម្រេចដោយការចំរើនភាវនា ។

### សិក្ខា ៣ យ៉ាង

១-សីលសិក្ខា សិក្ខា គឺសីល ។

២-សមាធិសិក្ខា សិក្ខា គឺសមាធិ ។

៣-បញ្ញាសិក្ខា សិក្ខា គឺបញ្ញា ។

### សីល ៣ យ៉ាង

១-និច្ចសីល បានដល់សីល ៥ ។

២-ឧបោសថសីល បានដល់សីល ៨ ។

៣-អតិរេកសីល ឬ និយមសីល បានដល់សីល ១០ ។

### សមាធិ ៣ យ៉ាង

១-ហីនសមាធិ សមាធិយ៉ាងទាប ។

២-មជ្ឈិមសមាធិ សមាធិយ៉ាងកណ្ដាល ។

៣-បណីតសមាធិ សមាធិយ៉ាងឧត្តម ។

### បញ្ញា ៣ យ៉ាង

១-ចិន្តាមយប្បញ្ញា ប្រាជ្ញាកើតអំពើការគិត ។

២-សុតាមយប្បញ្ញា ប្រាជ្ញាកើតអំពើការស្ដាប់ ការរៀន ។

៣-ភាវនាមយប្បញ្ញា ប្រាជ្ញាកើតអំពើការចំរើនភាវនា ។

### កល្យាណ "សេចក្ដីល្អ" ៣ យ៉ាង

១-អាទិកល្យាណ ល្អក្នុងខាងដើមគឺសីល ។

២-មជ្ឈេកល្យាណ ល្អក្នុងកណ្ដាលគឺសមាធិ ។

៣-បរិយោសានកល្យាណ ល្អក្នុងទីបំផុតគឺបញ្ញា ។

### អនុត្តរិយ ៣ យ៉ាង

១-ទស្សនានុត្តរិយ ការឃើញជាការប្រសើរ ។

២-បដិបទានុត្តរិយ សេចក្ដីរបតិបត្តិដ៏ប្រសើរ ។

៣-វិមុត្តានុត្តរិយ ការរួចក៏ប្រសើរចាកកិលេស ។

### សេចក្ដីឈ្លាស ៣ យ៉ាង

១-អាយកោសល្ល សេចក្ដីឈ្លាសក្នុងការចំរើន ។

២-បចាយកោសល្ល សេចក្ដីឈ្លាសក្នុងការវិនាស ។

៣-ឧបាយកោសល្ល សេចក្ដីឈ្លាសក្នុងកលឧបាយ ។

### សេចក្ដីលំបាក ៣ យ៉ាង

១-ទុក្ខទុក្ខតា លំបាកព្រោះសេចក្ដីទក្ខ ។

**២-សង្ខារទុក្ខតា** លំបាកព្រោះសង្ខារ ។

**៣-វិបរិណាមទុក្ខតា** លំបាកព្រោះសេចក្ដីប្រែប្រួល ។

### សាមញ្ញលក្ខណ ៣ យ៉ាង

**១-អនិច្ចតា** ភាវៈជារបស់មិនទៀង ។

**២-ទុក្ខតា** ភាវៈជាទុក្ខ ។

**៣-អនត្តតា** ភាវៈជារបស់មិនមែនខ្លួន ។

### ភ្លើង ៣ យ៉ាង

**១-រាគគ្គិ** ភ្លើងគឺរាគ ។

**២-ទោសគ្គិ** ភ្លើងគឺទោស ។

**៣-មោហគ្គិ** ភ្លើងគឺមោហ ។

**រាគៈ ទោសៈ មោហៈ** នេះមានឈ្មោះហៅបានច្រើនយ៉ាងថា **គញ្ជិន**"កង្វល់"ខ្លះ **អង្គណ**"ទួល"ខ្លះ **មល**"មន្ទិល"ខ្លះ **វិសម**"ការមិនស្មើ"ខ្លះ

### ភ្លើង ៣ យ៉ាងទៀត

**១-អាហុនេយ្យគ្គិ** ភ្លើងគឺអាហុនេយ្យបុគ្គល បានដល់មាតាបិតា ។

**២-ទក្ខិណេយ្យគ្គិ** ភ្លើងគឺទក្ខិណេយ្យបុគ្គល បានដល់ព្រះអរហន្ត ។

**៣-គហបតគ្គិ** ភ្លើងគឺគហបតី បានដល់ជនជាម្ចាស់ផ្ទះ ។

### ប្រយោជន៍ ៣ យ៉ាង

**១-ទិដ្ឋធម្មិកត្ថ** ប្រយោជន៍ក្នុងបច្ចុប្បន្ន ។

**២-សម្បរាយិកត្ថ** ប្រយោជន៍ក្នុងបរលោក ។

**៣-បរមត្ថ** ប្រយោជន៍ដ៏ឧត្តម គឺព្រះនិព្វន ។

### វិរតិ "ចេតនាវៀរចាកបាប" ៣ យា□៉ង

**១-សមាទានវិរតិ** វៀរចាកបាប ដោយអំណាចសមាទាន ។

**២-សម្បត្តវិរតិ** វៀរចាកបាប ក្នុងពេលដែលជួបប្រទះ ។

**៣-សមុច្ឆេទវិរតិ** វៀរចាកបាប ដោយដាច់ស្រឡះ ។

### វត្ថុដែលមិនចេះឆ្អែតមាន ៣ យ៉ាង

**១-អគ្គិឧបាទានេន** ភ្លើងមិនចេះឆ្អែតដោយគ្រឿងឆេះ ។

**២-សមុទ្ទោ ឧទកេន** សមុទ្រមិនចេះឆ្អែតដោយទឹក ។

**៣-មហិច្ឆោ បច្ចយេហិ** អ្នកប្រាថ្នាធំមិនចេះឆ្អែតដោយបច្ច័យ ។

### លក្ខណៈរបស់មិត្រ ៣ យ៉ាង

**១-អហិតោ បដិសេធោ** ហាមឃាត់មិត្តឱ្យឃ្លាតពីអំពើដែលមិនមានប្រយោជន៍ ។

**២-ហិតេ អនុប្បវត្តនំ** ដឹកនាំមិត្តអោយប្រព្រឹត្តអំពើដែលមានប្រយោជន៍ ។

**៣-ព្យសនេ អបរិច្ចាគោ** មិនលះបង់ចោលមិត្រ ក្នុងកាលដែលមានសេចក្ដីវិនាស ។

### ចរិយារបស់ព្រះពោធិសត្វ ៣ យ៉ាង

១-លោកត្ថចរិយា ប្រព្រឹត្តប្រយោជន៍ដើម្បីលោក ។

២-ញាតត្ថចរិយា ប្រព្រឹត្តប្រយោជន៍ដើម្បីញាតិ ។

៣-ពុទ្ធត្ថចរិយា ប្រព្រឹត្តប្រយោជន៍ដើម្បីត្រាស់ដឹង ។

**ចក្ខុ(ភ្នែក) ៣ យ៉ាង**

១-មំសចក្ខុ ភ្នែកសាច់ (ដែលជាប់នៅនឹងកាយ) ។

២-ទិព្វចក្ខុ ភ្នែកទិព្វ ។

៣-បញ្ញាចក្ខុ ភ្នែកគឺប្រាជ្ញា ។

**ទេវតា ៣ ពួក**

១-សម្មតិទេវ ទេវតាដោយសម្មត បានដល់មហាក្សត្រ ។

២-ឧបបត្តិទេវ ទេវតាកើតដោយបុញ្ញកម្ម បានដល់ទេវតាក្នុងស្ថានសួគ៌ ។

៣-វិសុទ្ធិទេវ ទេវតាបរិសុទ្ធ បានដល់ព្រះអរហន្ត ។

**វិបល្លាស "ការភ្លាត់" ៣ យ៉ាង**

១-សញ្ញាវិបល្លាស ភ្លាត់សញ្ញា ។

២-ចិត្តវិបល្លាស ភ្លាត់ចិត្ត ។

៣-ទិដ្ឋិវិបល្លាស ភ្លាត់ទិដ្ឋិ ។

**អនុសយ "កិលេសដែលដេកនៅក្នុងចិត្ត" ៣ យ៉ាង**

១-កាមរាគានុសយ បានដល់សេចក្តីរីករាយក្នុងកាម ។

២-បដិឃានុសយ បានដល់សេចក្តីថ្នាំងថ្នាក់ក្នុងចិត្ត ។

៣-អវិជ្ជានុសយ បានដល់អវិជ្ជា ។

**សន្តោស ៣ យ៉ាង**

១-យថាលាភសន្តោស ត្រេកអរតាមមានតាមបាន ។

២-យថាពលសន្តោស ត្រេកអរតាមកំលាំង ។

៣-យថាសារុប្បសន្តោស ត្រេកអរតាមសំគួរ ។

**ភារៈ "គ្រឿងធ្ងន់" ៣ យ៉ាង**

១-ខន្ធភារៈ គ្រឿងធ្ងន់ គឺខន្ធ ។

២-កិលេសភារៈ គ្រឿងធ្ងន់ គឺកិលេស ។

៣-អភិសង្ខារភារៈ គ្រឿងធ្ងន់ គឺអភិសង្ខារ ។

**វិជ្ជា ៣ យ៉ាង**

១-បុព្វេនិវាសានុស្សតិញ្ញាណ បញ្ញាតាមរលឹកឃើញនូវខន្ធដែលខ្លួននឹងសត នឹងសត្វដ៏ទៃងាស្រ័យនៅហើយក្នុងកាលមុន ។

២-ចុតូបបាតញ្ញាណ បញ្ញាដឹងនូវចុតិបដិសន្ធិនៃសត្វ ។

៣-អាសវក្ខយញ្ញាណ បញ្ញាដឹងនូវធម៌ជាគ្រឿងអស់នៃអាសវៈ ។

**ចតុក្កៈ ពួកធម៌ ៤**

**ព្រះពុទ្ធ ៤ ពួក**

១-ព្រះសព្វញ្ញុពុទ្ធ

២-ព្រះបច្ចេកពុទ្ធ

៣-ព្រះសុតពុទ្ធ

៤-ព្រះសាវតពុទ្ធ

ព្រះអរហន្ត ៤ ពួក

**១-សុក្ខវិបស្សកោ** លោកធ្វើកិលេសឱ្យស្ងួតដោយវិបស្សនា ។

**២-តេវិជ្ជោ** លោកបាននូវវិជ្ជា ៣ ។

**៣-ឆឡភិញ្ញោ** លោកបាននូវអភិញ្ញា ៦ ។

**៤-បដិសម្ភិទប្បត្តោ** លោកដល់នូវបដិសម្ភិទា ៤ ។

បុគ្គល ៤ ពួក

**១-កោធគរុ ន សទ្ធម្មគរុ** ធ្ងន់ក្នុងសេចក្តីក្រោធ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ។

**២-មក្ខគរុ ន សទ្ធម្មគរុ** ធ្ងន់ក្នុងសេចក្តីលប់គុណ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ។

**៣-លាភគរុ ន សទ្ធម្មគរុ** ធ្ងន់ក្នុងលាភ មិនធ្ងន់ក្នុងព្រះសទ្ធម្ម។

**៤-សក្ការគរុ ន សទ្ធម្មគរុ** ធ្ងន់ក្នុងសក្ការៈ មិនធ្ងន់ក្នុងព្រះសទ្ធម្ម ។

បុគ្គល ៤ ពួកទៀត

**១-អត្តហិតាយ បដិបន្នោ នោ បរហិតាយ** ប្រតិបត្តិដើម្បីខ្លួនមិនប្រតិបត្តិដើម្បីអ្នកដទៃ ។

**២-បរហិតាយ បដិបន្នោ នោ អត្តហិតាយ** ប្រតិបត្តិដើម្បីអ្នកដទៃមិនប្រតិបត្តិដើម្បីខ្លួន ។

**៣-នេវ អត្តហិតាយ បដិបន្នោ នោ បរហិតាយ** មិនប្រតិបត្តិដើម្បីខ្លួនទាំងមិនប្រតិបត្តិដើម្បីអ្នកដទៃ ។

**៤-អត្តហិតាយ បដិបន្នោ បរហិតាយ ច** ប្រតិបត្តិ ដើម្បីខ្លួនផង ដើម្បីអ្នកដទៃផង ។

បុគ្គល ៤ ពួកទៀត

**១-តមោ តមបរាយនោ** ជាមនុស្សងងឹត មានងងឹតទៅមុខ ។

**២-តមោ ជោតិបរាយនោ** ជាមនុស្សងងឹតមានពន្លឺភ្លឺស្វាងទៅមុខ ។

**៣-ជោតិ តមបរាយនោ** ជាមនុស្សភ្លឺស្វាង មានងងឹតទៅមុខ ។

**៤-ជោតិ ជោតិបរាយនោ** ជាមនុស្សភ្លឺស្វាងមានពន្លឺភ្លឺស្វាងទៅមុខ។

**សំវាស** " ការនៅរួមគ្នា " **៤យ៉ាង**

**១-ឆវោ ឆវាយ សទ្ធឹ សំវសតិ** ខ្មោចប្រុសនៅជាមួយនិងខ្មោចស្រី។

**២-ឆវោ ទេវិយា សទ្ធឹ សំវសតិ** ខ្មោចប្រុស នៅជាមួយនិងទេវតាស្រី ។

**៣-ទេវោ ឆវាយ សទ្ធឹ សំវសតិ** ទេវតាប្រុស នៅជាមួយនិងខ្មោចស្រី ។

**៤-ទេវោ ទេវិយា សទ្ធឹ សំវសតិ** ទេវតាប្រុស នៅជាមួយនិងទេវតាស្រី ។

បុគ្គល ៤ ពួក

១-អសុរោ អសុរបរិវារោ អសុរ មានអសុរជាបរិវា ។
២-អសុរោ ទេវបរិវារោ អសុរ មានទេវតាជាបរិវា ។
៣-ទេវោ អសុរបរិវារោ ទេវតា មានអសុរជាបរិវា ។
៤-ទេវោ ទេវបរិវារោ ទេវតា មានទេវតាជាបរិវា ។

### បុគ្គលប្រៀប និង វលាហក: ៤ យ៉ាង

១-គជ្ជិតា នោ វស្សិតា គ្រាន់តែផ្គរលាន់ តែមិនភ្លៀង ។
២-វស្សិតា នោ គជ្ជិតា ស្រាប់តែភ្លៀង ឥតផ្គរលាន់ ។
៣-នេវ គជ្ជិតា នោ វស្សិតា គ្មានទាំងផ្គរលាន់គ្មានទាំងភ្លៀង។
៤-គជ្ជិតា ច វស្សិតា ច ផ្គរលាន់ផងភ្លៀងផង ។

### បុគ្គលប្រៀប និង ក្អម ៤ យ៉ាង

១-តុច្ឆោ បិហិតោ ក្អមទទេ បិទជិត ។
២-បូរោ វិវដោ ក្អមមានទឹកពេញបើកចំហ ។
៣-តុច្ឆោ វិវដោ ក្អមទទេ បើកចំហ ។
៤-បូរោ បិហិតោ ក្អមមានទឹកពេញ បិទជិត ។

### បុគ្គលប្រៀប និង ផ្លែស្វាយ ៤ យ៉ាង

១-អាមោ បក្កវណ្ណី ខ្ចីទេ តែមានសម្បុរសដូចទុំ ។
២-បក្កោ អាមវណ្ណី ទុំ តែមានសម្បុរដូចខ្ចី ។
៣-អាមោ អាមវណ្ណី ខ្ចី មានសម្បុរក៏ខ្ចី ។
៤-បក្កោ បក្កវណ្ណី ទុំ មានសម្បុរក៏ទុំ ។

### បុគ្គលប្រៀប និង ដើមឈើ ៤ យ៉ាង

១-ផេគ្គុ ផេគ្គុបរិវារោ ឈើស្រាល មានឈើស្រាលជាបរិវា ។
២-ផេគ្គុ សារបរិវារោ ឈើស្រាល មានឈើខ្លឹមជាបរិវា ។
៣-សារោ ផេគ្គុបរិវារោ ឈើខ្លឹម មានឈើស្រាលជាបរិវា ។
៤-សារោ សារបរិវារោ ឈើខ្លឹម មានឈើខ្លឹមជាបរិវា ។

### បុគ្គលសមគួរដល់ស្តូប ៤ ពួក

១.ព្រះអរហំសម្មាសម្ពុទ្ធ
២.ព្រះបច្ចេកពុទ្ធ
៣.ព្រះអរហន្ត
៤.ស្តេចចក្រពត្តិ

### បុគ្គលមិនល្អ ៤ ពួក

១-អលសោ គិហិ កាមភោគី ន សាធុ គ្រហស្ថអ្នកបរិភោគកាមខ្ជិលច្រអូស ឈ្មោះថាមិនល្អ ។
២-អសញ្ញតោ បព្វជិតោ ន សាធុ អ្នកបួសមិនសង្រួមឈ្មោះថាមិនល្អ ។
៣-រាជា ន សាធុ អនិសម្មការី ព្រះរាជាមិនពិចារណាមុនចេះតែធ្វើទៅ ។ ឈ្មោះថាមិនល្អ ។
៤-យោ បណ្ឌិតោ កោធនោ តំ ន សាធុ អ្នកប្រាជ្ញដែលក្រៀវក្រោធច្រើន ក៏ឈ្មោះថាមិនល្អ ។

### មិត្តគួរគេបំគួររាប់រក ៤ ពួក

**១-ឧបការកោ** មិត្តមានឧបការៈ ។

**២-សមានសុខទុក្ខោ**

**៣-អត្ថក្ខាយី** មិត្តណែនាំប្រាប់ប្រយោជន៍ ។

**៤-អនុកម្បកោ** មិត្តមានសេចក្តីឈឺឆ្អាល ។

( មិត្រទាំង ៤ ពួកនេះ ហៅថាមិត្តមានចិត្តល្អ )

**មិត្តមិនគួរគប់មិនគួររាប់ ៤ ពួក**

**១-អញ្ញទត្ថុហរោ** មិត្រគិតយកតែប្រយោជន៍ខ្លួន ។

**២-វចីបរមោ** មិត្តល្អតែសំដី ល្អតែមាត់ ។

**៣-អនុប្បិយភាណី** មិត្រនិយាយចាក់បណ្តោយឱ្យគាប់ចិត្ត ។

**៤-អបាយសហាយោ** មិត្តជាសម្លាញ់ក្នុងផ្លូវវិនាស ។

**អបាយមុខ** "ហេតុជាប្រធាននៃសេចក្តីវិនាស" **៤ យ៉ាង**

**១-ឥត្ថីធុត្ត** ជាអ្នកលេងស្រី ។

**២-សុរាធុត្ត** ជាអ្នកផឹកសុរា ។

**៣-អក្ខធុត្ត** ជាអ្នកលេងល្បែងភ្នាល់ ។

**៤-បាបមិត្ត** គប់រកយកមនុស្សអាក្រក់ជាមិត្ត ។

**សេចក្តីប្រាថ្នារបស់មនុស្សក្នុងលោក ៤ យ៉ាង**

**១-** ចង់ឱ្យមានទ្រព្យសម្បត្តិកើតឡើងដោយត្រូវទំនង ។

**២-** ចង់ឱ្យមានយសសក្តិកើតឡើងដល់ខ្លួននិងញាតិមិតរបស់ខ្លួន ។

**៣-** ចង់ឱ្យអាយុបានស្ថិតនៅយឺនយូរ ។

**៤-** កាលបើអស់អាយុទៅ ចង់ឱ្យបានកើតក្នុងស្ថានសួគ៌ ។

( សេចក្តីប្រាថ្នាទាំង ៤ នេះអាចសម្រេចបានដោយធម៌ ៤ យ៉ាងគឺ **សទ្ធា, សីល, ចាគ, បញ្ញា** )

**យោគ ៤ យ៉ាង**

**១-កាមយោគ** កិលេសជាគ្រឿងប្រកប គឺកាម ។

**២-ភវយោគ** កិលេសជាគ្រឿងប្រកប គឺភព ។

**៣-ទិដ្ឋិយោគ** កិលេសជាគ្រឿងប្រកប គឺទិដ្ឋិ ។

**៤-អវិជ្ជាយោគ** កិលេសជាគ្រឿងប្រកប គឺអវិជ្ជា ។

( យោគទាំង ៤ នេះហៅថា"**អាសវៈ**"ខ្លះថា "**ឱឃៈ**" )

**បធាន** "សេចក្តីព្យាយាម" **៤ យ៉ាង**

**១-សំវរប្បធាន** ព្យាយាមក្នុងការប្រយ័ត្នមិនឱ្យបាបកើតឡើង ។

**២-បហានប្បធាន** ព្យាយាមក្នុងការលះបាបដែលកើតឡើង ។

**៣-ភាវនាបធាន** ព្យាយាមក្នុងការធ្វើកុសលអោយកើតឡើង ។

**៤-អនុរក្ខនាបធាន** ព្យាយាមក្នុងការរក្សាកុសលដែលកើតឡើងហើយ មិនឱ្យវិនាសបាត់ទៅវិញ ។

**អគតិ** "ការលំអៀង" **៤ យ៉ាង**

**១-ឆន្ទាគតិ** លំអៀងព្រោះសេចក្តីស្រឡាញ់ ។

២-ទោសាគតិ លំអៀងព្រោះសេចក្ដីស្អប់ ។

៣-មោហាគតិ លំអៀងព្រោះសេចក្ដីល្ងង់ខ្លៅ ។

៤-ភយាគតិ លំអៀងព្រោះសេចក្ដីខ្លាច ។

### ចក្ក "ធម៌ដូចជាកងវិលទៅកាន់សេចក្ដីល្អ" ៤ យ៉ាង

១-បដិរូបទេសវាសោ នៅក្នុងប្រទេសដ៏សមគួរ ។

២-សប្បុរិសូបស្សយ ការសេពគប់ពឹងផ្អែកនឹងសប្បុរស ។

៣-អត្តសម្មាបណិធិ ការដំកល់ខ្លួនដោយប្រពៃ ។

៤-បុព្វេកតបុញ្ញតា ភាពនៃបុគ្គលបានធ្វើបុណ្យទុកកាលមុន ។

### សង្គហវត្ថុ ៤ យ៉ាង

១-ទាន ការឱ្យនូវវត្ថុរបស់ខ្លួនដល់អ្នកដ៏ទៃដែលគួរអោយ ។

២-បិយវាចា ពោលពាក្យផ្អែមពិរោះគួរជាទីស្រឡាញ់ ។

៣-អត្ថចរិយា ប្រព្រឹត្តធ្វើអំពើដែលជាប្រយោជន៍ដល់អ្នកដ៏ទៃ ។

៤-សមានត្តតា ភាពជាអ្នកមានខ្លួនស្មើ មិនប្រកាន់ខ្លួន ។

### ការជ្រះថ្លាក្នុងវត្ថុដ៏ប្រសើរ ៤ យ៉ាង

១-ពុទ្ធេបសន្នា ជ្រះថ្លាចំពោះព្រះពុទ្ធ ។

២-អដ្ឋង្គិកេ មគ្គេ បសន្នា ជ្រះថ្លាចំពោះមគ្គមានអង្គ ៨ ។

៣-វិរាគេ ធម្មេ បសន្នា ជ្រះថ្លាចំពោះធម៌ប្រាសចាករាគ គឺព្រះនិព្វាន ។

៤-សង្ឃេ បសន្នា ជ្រះថ្លាចំពោះព្រះសង្ឃ ។

### ការហូរមកនៃបុណ្យ ៤ យ៉ាង

១-ពុទ្ធេ អវេច្ចប្បសាទេន ដោយសេចក្ដីជ្រះថ្លា មិនកក្រើកចំពោះព្រះពុទ្ធ ។

២-ធម្មេ អវេច្ចប្បសាទេន ដោយសេចក្ដីជ្រះថ្លា មិនកក្រើកចំពោះព្រះធម៌ ។

៣-សង្ឃេ អវេច្ចប្បសាទេន ដោយសេចក្ដីជ្រះថ្លា មិនកក្រើកចំពោះព្រះសង្ឃ ។

៤-អរិយកន្តេហិ សីលេហិ ដោយសីលដែលព្រះអរិយលោកប្រាថ្នា គឺសីលមិនពព្រុះពពាល ។

### អចិន្តេយ្យ ឬ អចិន្ត្រៃយ "ហេតុមិនគួរគិត" ៤ យ៉ាង

១-ពុទ្ធវិសយ វិស័យរបស់ព្រះពុទ្ធ ។

២-ឈានវិសយ វិស័យរបស់ឈាន ។

៣-កម្មវិបាក ផលរបស់កម្ម ។

៤-លោកចិន្តា ការគិតអំពីលោក ឬ ការគិតរបស់សត្វលោក ។

### សំវេជនីយដ្ឋាន ៤ យ៉ាង

១-កន្លែងដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រសូត ។

២-កន្លែងដែលព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់ ។

៣-កន្លែងដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងព្រះធម្មចក្រ ។

៤-កន្លែងដែលព្រះសម្មាសម្ពុទ្ធទ្រង់និព្វាន ។

## ភ័យ ៤ យ៉ាង

១-ជាតិភយ ភ័យអំពីការកើត ។

២-ជរាភយ ភ័យអំពីចាស់គ្រាំគ្រា ។

៣-ព្យាធិភយ ភ័យអំពីការឈឺចាប់ ។

៤-មរណភយ ភ័យអំពីសេចក្តីស្លាប់ ។

## ភ័យ ៤ យ៉ាងទៀត

១-អគ្គិភយ ភ័យអំពីភ្លើង ។

២-ឧទកភយ ភ័យអំពីទឹក ។

៣-រាជភយ ភ័យអំពីស្តេច ។

៤-ចោរភយ ភ័យអំពីចោរ ។

## ភ័យ ៤ យ៉ាងទៀត

១-អត្តានុវាទភយ ភ័យអំពីការតិះដៀលខ្លួនឯង ។

២-បរានុវាទភយ ភ័យអំពីការតិះដៀលអ្នកដទៃ ។

៣-ទណ្ឌភយ ភ័យអំពីអាជ្ញា ។

៤-ទុគ្គតិភយ ភ័យអំពីទុគ្គតិ ។

## អាភា "ពន្លឺ" ៤ យ៉ាង

១-ចន្ទាភា ពន្លឺព្រះចន្ទ ។

២-សុរិយាភា ពន្លឺព្រះសុរិយា ។

៣-អគ្យាភា ពន្លឺភ្លើង ។

៤-បញ្ញាភា ពន្លឺប្រាជ្ញា ។

(ពន្លឺប្រាជ្ញាប្រសើរជាងពន្លឺទាំង បី ខាងដើម)

## កាលដែលគួរប្រកប ៤ យ៉ាង

១-កាលេនធម្មស្សវនំ ស្តាប់ធម៌តាមកាល ។

២-កាលេនធម្មសាកច្ឆា សន្ទនាធម៌តាមកាល ។

៣-កាលេន សមថោ ស្ងប់រម្ងាប់តាមកាល ។

៤-កាលេន វិបស្សនា ចំរើនវិបស្សនាតាមកាល ។

## សារៈ "ខ្លឹម" ៤ យ៉ាង

១-សីលសារៈ ខ្លឹមគឺសីល ឬ សីលគឺជាខ្លឹម ។

២-សមាធិសារៈ ខ្លឹមគឺសមាធិ ឬ សមាធិគឺជាខ្លឹម ។

៣-បញ្ញាសារៈ ខ្លឹមគឺប្រាជ្ញា ឬ ប្រាជ្ញាជាខ្លឹម ។

៤-វិមុត្តិសារៈ ខ្លឹមគឺវិមុត្តិឬវិមុត្តិគឺធម៌រួចផុតចាកកិលេសជាខ្លឹម។

## សភាវធម៌ដែលគេហាមឃាត់មិនបាន ៤ យ៉ាង

១-ជរា ចាស់គ្រាំគ្រា ។

២-ព្យាធិ ជម្ងឺឈឺចាប់ ។

៣-មរណៈ សេចក្តីស្លាប់ ។

៤-វិបាក ផលកម្ម ។

## កំណើតនៃសេចក្តីស្រឡាញ់និងស្អប់ ៤ យ៉ាង

១-បេមា បេមំ ជាយតិ សេចក្តីស្រឡាញ់កើតពីសេចក្តីស្រឡាញ់

២-បេមា ទោសោ ជាយតិ សេចក្តីស្អប់កើតពីសេចក្តីស្រឡាញ់។

៣-ទោសោ បេមំ ជាយតិ សេចក្តីស្រឡាញ់កើតពីសេចក្តីស្អប់។

៤-ទោសោ ទោសោ ជាយតិ សេចក្តីស្អប់កើតពីសេចក្តីស្អប់ ។

**កម្ម ៤ យ៉ាង**

១-កម្មខ្មៅ អោយផលខ្មៅ ។

២-កម្មស អោយផលស ។

៣-កម្មទាំងខ្មៅទាំងស អោយផលទាំងខ្មៅទាំងស ។

៤-កម្មមិនខ្មៅមិនស អោយផលមិនខ្មៅមិនស ។

**ការសេពគប់និងសប្បុរសមានអានិសង្ស ៤ យ៉ាង**

១-អរិយេន សីលេន វឌ្ឍតិ តែងចំរើនដោយសីលដ៏ប្រសើរ ។

២-អរិយេន សមាធិនា វឌ្ឍតិ តែងចំរើនដោយសមាធិដ៏ប្រសើរ ។

៣-អរិយាយ បញ្ញាយ វឌ្ឍតិ តែងចំរើនដោយបញ្ញាដ៏ប្រសើរ ។

៤-អរិយាយ វិមុត្តិយា វឌ្ឍតិ តែងចំរើនដោយវិមុត្តិដ៏ប្រសើរ ។

**សេយ្យា "ដំណេក" ៤ យ៉ាង**

១-បេតសេយ្យា ដំណេកប្រេត (ដេកផ្ងារ) ។

២-កាមភោគិសេយ្យា

ដំណេកអ្នកបរិភោគកាម(ដេកផ្អៀងទៅខាង ឆ្វេង) ។

៣-សីហសេយ្យ ដំណេកសីហៈ(ដេកផ្អៀងទៅខាងស្តាំ) ។

៤-តថាគតសេយ្យា ដំណេកព្រះតថាគត(មានឈានជាអារម្មណ៍) ។

**បញ្ញាវុឌ្ឍិ "ធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីចំរើនប្រាជ្ញា" ៤ យ៉ាង**

១-សប្បុរិសូបសំសេវ សេពគប់រួមជាមួយនិងសប្បុរស ។

២-សទ្ធម្មស្សវន ស្តាប់ព្រះសទ្ធម្ម ។

៣-យោនិសោមនសិការៈ ធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ។

៤-ធម្មានុធម្មប្បដិបត្តិ ប្រតិបត្តិសមគួរដល់ធម៌ ។

**ទិដ្ឋធម្មិកត្ថ "ប្រយោជន៍ក្នុងលោកនេះ" ៤ យ៉ាង**

១-ឧដ្ឋានសម្បទា ដល់ព្រមដោយព្យាយាម ។

២-អារក្ខសម្បទា ដល់ព្រមដោយការថែរក្សា ។

៣-កល្យាណមិត្តតា ភាពជាអ្នកមានមិត្តល្អ ។

៤-សមជីវិតា ភាពជាអ្នកចិញ្ចឹមជីវិត តាមសមគួរដល់កម្លាំងទ្រព្យដែលរកបាន ។

**សម្បរាយិកត្ថ "ប្រយោជន៍ក្នុងលោកខាងមុខ" ៤ យ៉ាង**

១-សទ្ធាសម្បទា ដល់ព្រមដោយសទ្ធា ។

២-សីលសម្បទា ដល់ព្រមដោយសីល ។

៣-ចាគសម្បទា ដល់ប្រមដោយការបរិចាគទាន ។

៤-បញ្ញាសម្បទា ដល់ប្រមដោយបញ្ញា ។

## សម្បទាដែលធ្វើទានឱ្យបានផលក្នុងបច្ចុប្បន្ន ៤ យ៉ាង

**១-វត្ថុសម្បទា** ដល់ព្រមដោយវត្ថុគឺទក្ខិណេយ្យបុគ្គល ។

**២-បច្ចយសម្បទា** ដល់ព្រមដោយបច្ច័យ គឺ ទេយ្យវត្ថុ ។

**៣-ចេតនាសម្បទា** ដល់ព្រមដោយចេតនាទាំង ៣ ។

**៤-គុណាតិរេកសម្បទា** ដល់ព្រមដោយទក្ខិណេយ្យបុគ្គលដែលមានគុណដ៏លើសលប់គឺ លោកដែលចេញចាកសមាបត្តិ ។

## សទ្ធា ៤ យ៉ាង

**១-កម្មស្សទ្ធា** ជឿកម្ម ។

**២-វិបាកស្សទ្ធា** ជឿផលរបស់កម្ម ។

**៣-កម្មស្សកតាសទ្ធា** ជឿថាសត្វមានកម្មជារបស់ខ្លួន ។

**៤-តថាគតពោធិស្សទ្ធា** ជឿប្រាជ្ញាត្រាស់ដឹងរបស់ព្រះតថាគត ។

## លក្ខណៈសទ្ធា ៤ យ៉ាង

**១-សទ្ទហនលក្ខណា សទ្ធា** សទ្ធាមានជំនឿជាលក្ខណៈ ។

**២-បសាទលក្ខណា សទ្ធា** សទ្ធាមានសេចក្តីជ្រះថ្លាជាលក្ខណៈ ។

**៣-បក្ខន្ទលក្ខណា សទ្ធា** សទ្ធាមានកិរិយាលឿនទៅ ឬ ស្ទុះស្ទាជាលក្ខណៈ ។

**៤-ឱកប្បនលក្ខណា សទ្ធា** សទ្ធាមានកិរិយាតាំងមាំក្នុងវត្ថុដែលគួរជឿជាលក្ខណៈ ។

## ទក្ខិណាវិសុទ្ធិ មាន ៤ យ៉ាង

**១-ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ** ទក្ខិណាទាន បរិសុទ្ធអំពីអ្នកអោយ មិនបរិសុទ្ធអំពីអ្នកទទួល ។

**២-បដិគ្គាហកតោ វិសុជ្ឈតិ នោ ទាយកតោ** ទក្ខិណាទាន បរិសុទ្ធអំពីអ្នកទទួលមិនបរិសុទ្ធអំពីអ្នកអោយ ។

**៣-នេវ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ** ទក្ខិណាទានមិនបរិសុទ្ធអំពីអ្នកអោយ ទាំងមិនបរិសុទ្ធអំពីអ្នកទទួល ។

**៤-ទាយកតោ ចេវ វិសុជ្ឈតិ បដិគ្គាហកតោ ច** ទក្ខិណាទានបរិសុទ្ធអំពីអ្នកឱ្យផង អំពីអ្នកទទួលផង ។

## មរណៈ ៤ យ៉ាង

**១-អាយុក្ខយមរណៈ** ស្លាប់ដោយអស់អាយុ ។

**២-កម្មក្ខយមរណៈ** ស្លាប់ដោយអស់កម្ម ។

**៣-ឧភយក្ខយមរណៈ** ស្លាប់ដោយអស់អាយុ និងកម្មទាំងពីរ ។

**៤-ឧបច្ឆេទកកម្មុនា** ស្លាប់ដោយកម្មចូលមកកាត់បង់ ។

## ទេវតាច្យុតដោយហេតុ ៤ យ៉ាង

**១-អាយុក្ខយេន** ដោយអស់អាយុ ។

**២-បុញ្ញក្ខយេន** ដោយអស់បុណ្យ ។

**៣-អាហារក្ខយេន** ដោយអស់អាហារ ។

**៤-គោបេន** ដោយសេចក្តីរកវក្រោធ ។

### ឧបាទាន ៤ យ៉ាង

**១-កាមុប្បាទាន** សេចក្តីរបកាន់មាំដោយអំណាចនៃកាម ។

**២-ទិដ្ឋុប្បាទាន** សេចក្តីរបកាន់មាំដោយអំណាចនៃទិដ្ឋី ។

**៣-សីលព្វតុប្បាទាន** សេចក្តីរបកាន់មាំដោយអំណាចនៃការជឿ ប្រកាន់សីលវត ។

**៤-អត្តវាទុប្បាទាន** សេចក្តីរបកាន់មាំដោយអំណាចនៃអត្តវាទ គឺ ពាក្យពោលថា"អត្តា។" ឬពោលប្រារព្ធយកខ្លួនជាធំ ។

### កូន ៤ ពួក

**១-អត្តជ** កូនដែលកើតអំពីខ្លួន ។

**២-ខេត្តជ** កូនដែលកើតក្នុងទីជាខេត្ត ។

**៣-ទិន្នក** កូនដែលគេអោយ ឬ កូនសុំគេ ។

**៤-អន្តេវាសិក** កូនសិស្ស ។

### ឧបក្កិលេសព្រះអាទិត្យ ព្រះចន្ទ ៤ យ៉ាង

**១-អព្ភា** ពពក ។

**២-មហិកា** ទឹកសន្សើម ។

**៣-ធូមរជោ** ផ្សែង និងធូលី ។

**៤-រាហុ** រាហុ ។

### ឧបក្កិលេសសមណព្រាហ្មណ៍ ៤ យ៉ាង

**១-**ផឹកសុរា មេរ័យ

**២-**សេពមេថុន

**៣-**ត្រេកអរនឹងរូបបិយៈ

**៤-**មិច្ឆាទិដ្ឋិ

### ហេតុដែលនាំឱ្យកើតហិរិ"សេចក្តីខ្មាស់បាប" ៤ យ៉ាង

**១-ជាតឹ បច្ចវេក្ខិត្វា** ព្រោះពិចារណានូវជាតិ ។

**២-វយំ បច្ចវេក្ខិត្វា** ព្រោះពិចារណានូវវ័យ ។

**៣-សូរភាវំ បច្ចវេក្ខិត្វា** ព្រោះពិចារណានូវសេចក្តីក្លៀវក្លា ។

**៤-ពាហុសច្ចំ បច្ចវេក្ខិត្វា** ព្រោះពិចារណានៅពហុស្សូត្រ ។

### អយោនិសោមនសិការ ៤ យ៉ាង

**១-អនិច្ចេ និច្ចន្តិ** ថាទៀង ក្នុងចំណែកមិនទៀង ។

**២-ទុក្ខេ សុខន្តិ** ថាសុខ ក្នុងចំណែកដែលជាទុក្ខ ។

**៣-អនត្តនិ អត្តាតិ** ថាជាអនត្តា ក្នុងចំណែកដែលមិនមែនជាអនត្តា ។

**៤-អសុភេ សុភន្តិ** ថាល្អ ក្នុងចំណែកដែលមិនល្អ ។

### ធម៌សម្រាប់ផ្ចាញ់សត្រូវបាន ៤ យ៉ាង

**១-សច្ច** ពោលពាក្យពិត ។

**២-ធម្ម** ប្រាជ្ញាចេះពិចារណា ។

**៣-ធិតិ** ព្យាយាមមាំមួន ។

៤-ចាគ ការស៊ូលះបង់ជីវិត ។

## អរិយសច្ច ៤ យ៉ាង

១-ទុក្ខអរិយសច្ច សេចក្ដីទុក្ខជាធម៌ពិតរបស់ព្រះអរិយៈ ។
២-សមុទយអរិយសច្ច តណ្ហាជាធម៌ពិតរបស់ព្រះអរិយៈ ។
៣-និរោធអរិយសច្ច និរោធជាធម៌ពិតរបស់ព្រះអរិយៈ ។
៤-មគ្គអរិយសច្ច មគ្គជាធម៌ពិតរបស់ព្រះអរិយៈ ។

## កិច្ចក្នុងអរិយសច្ច ៤ យ៉ាង

១-បរិញ្ញាកិច្ច សេចក្ដីទុក្ខជាកិច្ចគួរកំណត់ដឹង ។
២-បហានកិច្ច តណ្ហាជាកិច្ចគួរលះបង់ ។
៣-សច្ឆិកិរិយាកិច្ច និរោធជាកិច្ចគួរធ្វើអោយជាក់ច្បាស់ ។
៤-ភាវនាកិច្ច មគ្គជាកិច្ចគួរចំរើន ។

## ញាណ ៤ យ៉ាង

១-ទុក្ខេ ញាណំ ដឹងក្នុងកងទុក្ខ ។
២-ទុក្ខសមុទយេ ញាណំ ដឹងក្នុងទុក្ខសមុទយៈ ។
៣-ទុក្ខនិរោធេ ញាណំ ដឹងក្នុងទុក្ខនិរោធ ។
៤-ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ ដឹងក្នុងទុក្ខនិរោធគាមិនីបដិបទា ។

## បច្ច័យ ៤ នៃបញ្ចក្ខន្ធ

១.អវិជ្ជា ២ តណ្ហា ៣ កម្ម ៤ អាហារ ជាបច្ច័យរបស់រូប ។
១.អវិជ្ជា ២ តណ្ហា ៣ កម្ម ៤ ផស្ស ជាបច្ច័យរបស់វេទនា ។
១.អវិជ្ជា ២ តណ្ហា ៣ កម្ម ៤ ផស្ស ជាបច្ច័យរបស់សញ្ញា ។
១.អវិជ្ជា ២ តណ្ហា ៣ កម្ម ៤ ផស្ស ជាបច្ច័យរបស់សង្ខារ ។
១.អវិជ្ជា ២ តណ្ហា ៣ កម្ម ៤ នាមរូប ជាបច្ច័យរបស់វិញ្ញាណ

## បដិសម្ភិទា ៤ យ៉ាង

១-អត្ថប្បដិសម្ភិទា ប្រាជ្ញាដែលបែកចំពោះក្នុងអត្ថ ។
២-ធម្មប្បដិសម្ភិទា ប្រាជ្ញាដែលបែកចំពោះក្នុងធម៌ ។
៣-និរុត្តិប្បដិសម្ភិទា ប្រាជ្ញាដែលបែកចំពោះក្នុងភាសានិយាយ ។
៤-បដិភាណប្បដិសម្ភិទា ប្រាជ្ញាដែលបែកចំពោះក្នុងបដិភាណ ។

## វិធីផ្ចាញ់ ៤ យ៉ាង

១-អក្កោធេន ជិនេ កោធំ ផ្ចាញ់មនុស្សក្រោធដោយមិនក្រោធ។
២-អសាធុំ សាធុនា ជិនេ ផ្ចាញ់មនុស្សអាក្រក់ដោយសេចក្ដីល្អ។
៣-ជិនេ កទរិយំ ទានេន ផ្ចាញ់មនុស្សកំណាញ់ដោយការឱ្យ ។
៤-សច្ចេនាលិកវាទិនំ ផ្ចាញ់មនុស្សនិយាយកុហក់ដោយពាក្យពិត។

## អបស្សេនធម៌ "ធម៌គួរពឹងផ្អែក" ៤ យ៉ាង

១-សង្ខាយេកំ បដិសេវតិ ពិចារណាមុនសិន សឹមសេព ។
២-សង្ខាយេកំ អធិវាសេតិ ពិចារណាមុនសិន សឹមអត់ធន់ ។
៣-សង្ខាយេកំ បរិវជ្ជេតិ ពិចារណាមុនសិន សឹមវៀរ ។
៤-សង្ខាយេកំ វិនោទេតិ ពិចារណាមុនសិន សឹមបន្ទោបង់ ។

### ធម៌របស់គ្រហស្ថ ៤ យ៉ាង

១-សច្ចៈ ពោលពាក្យពិតប្រាកដ ។

២-ទម ចេះទូន្មានចិត្ត ឬ ទប់ចិត្តរបស់ខ្លួន ។

៣-ខន្តី អត់ធន់ ។

៤-ចាគ លះបង់ទ្រព្យរបស់ខ្លួន ឱ្យដល់អ្នកដែលគួរអោយ ។

### កម្មកិលេស ៤ យ៉ាង

១-បាណាតិបាត សម្លាប់សត្វ ។

២-អទិន្នាទាន លួចទ្រព្យគេ ។

៣-កាមេសុ មិច្ឆាចារ ប្រព្រឹត្តខុសក្នុងកាម ។

៤-មុសាវាទ និយាយពាក្យកុហក់ ។

### អ្នកដែលប្រកបដោយធម៌ ៤ ហៅថាបណ្ឌិត

១-សុត "ស្តាប់" ។

២-ចិន្ត "គិត" ។

៣-បុច្ឆា "សួរ" ។

៤-លិខិត "សរសេរ" ។

(សុ. ចិ. បុ. លិ. )

### វិបត្តិ ៤ យ៉ាង

១-សីលវិបត្តិ ខូចសីល ។

២-អាចារវិបត្តិ ខូចមាយាទ ។

៣-ទិដ្ឋិវិបត្តិ ខូចទិដ្ឋិ ។

៤-អាជីវវិបត្តិ ខូចអាជីវៈ គឺចិញ្ចឹមជីវិតខុសធម៌ ។

### កម្លាំង ៤ ប្រការ

១-បញ្ញាពលំ កម្លាំងប្រាជ្ញា ។

២-វិរិយពលំ កម្លាំងសេចក្តីព្យាយាម ។

៣-អនវជ្ជពលំ កម្លាំងកិច្ចដែលមិនមានទោស ។

៤-សង្គហពលំ កម្លាំងសេចក្តីសង្គ្រោះ ។

### បរិសុទ្ធិ ៤ យ៉ាង

១-ទេសនាបរិសុទ្ធិ បរិសុទ្ធិដោយការសំដែងអាបត្តិ ។

២-សំវរបរិសុទ្ធ បរិសុទ្ធិដោយការសង្រួម ។

៣-បរិយដ្ឋិតបរិសុទ្ធិ បរិសុទ្ធិដោយការស្វែងរកអាហារ ។

៤-បច្ចវេក្ខណបរិសុទ្ធិ បរិសុទ្ធិដោយការពិចារណា ។

### លោកិយសរណគមន៍សម្រេចដោយអាការៈ ៤ យ៉ាង

១-អត្តនិយ្យាតន ប្រគល់កាយថ្វាយជីវិត ។

២-តប្បរាយនតា យកគុណព្រះរតនត្រ័យជាទីពឹងទៅមុខ ។

៣-សិស្សភាវូបគមន ប្រគល់ខ្លួនជាសិស្ស ។

៤-បណិបាត គោរពព្រះរតនត្រ័យដរាបអស់ជីវិត ។

### កំណប់ទ្រព្យ ៤ យ៉ាង

១-ថាវរនិធិ កំណប់ទ្រព្យដ៏មាំមួន(បានខាងអសង្ខារិមវត្ថុ) ។

២-ជង្គមនិធិ កំណប់ទ្រព្យដើរបាន(បានខាងសង្ហារិមវត្ថុ) ។

៣-អង្គសមនិធិ កំណប់ទ្រព្យស្មើរដោយអង្គ(វនខាងចំណេះវិជ្ជា) ។

៤-អនុគាមិកនិធិ កំណប់ទ្រព្យអាចជិតដោយតាមខ្លួនទៅ(បានខាងបុណ្យដែលខ្លួនបានសាងទុក) ។

## អង្គរបស់បណ្ឌិត ៤ យ៉ាង

១-កតញ្ញូ ដឹងឧបការគុណដែលគេបានធ្វើដល់ខ្លួន ។

២-អត្តសុទ្ធិ ធ្វើខ្លួនឱ្យបរិសុទ្ធចាកបាប ។

៣-បរិសុទ្ធិ ធ្វើអ្នកដ៏ទៃអោយបរិសុទ្ធ ។

៤-សង្គហ សង្គ្រោះដល់ជនដែលគួរសង្គ្រោះ ។

## អារក្ខកម្មដ្ឋាន ៤ យ៉ាង

១-ពុទ្ធានុស្សតិ រលឹកដល់គុណព្រះពុទ្ធ ។

២-មេត្តា ផ្សាយមេត្តាចិត្តដល់ពពួកសត្វ ។

៣-អសុភ ពិចារណារាងកាយឱ្យឃើញថាមិនល្អ ។

៤-មរណស្សតិ រលឹកដល់សេចក្តីស្លាប់ ។

## សតិបដ្ឋាន ៤

១-កាយានុបស្សនា តាំងស្មារតីពិចារណាកាយ ។

២-វេទនានុបស្សនា តាំងស្មារតីពិចារណាវេទនា ។

៣-ចិត្តានុបស្សនា តាំងស្មារតីពិចារណាចិត្ត ។

៤-ធម្មានុបស្សនា តាំងស្មារតីពិចារណាធម៌ ។

## គួរធ្វើសេចក្តីមិនប្រមាទក្នុងទី ៤ ស្ថាន

១-មិនប្រមាទក្នុងការលះកាយទុច្ចរិត ធ្វើកាយសុចរិតអោយកើត ។

២-មិនប្រមាទក្នុងការលះវចីទុច្ចរិត ធ្វើវចីសុចរិតអោយកើត ។

៣-មិនប្រមាទក្នុងលះមនោទុច្ចរិ ធ្វើមនោសុចរិអោយកើត ។

៤-មិនប្រមាទក្នុងការលះមិច្ឆាទិដ្ឋិ ធ្វើសម្មាទិដ្ឋិអោយកើត ។

## ភាសិត ៤ យ៉ាង

១-ពុទ្ធភាសិត ធម៌ដែលព្រះពុទ្ធទ្រង់សំដែង ។

២-សាវកភាសិត ធម៌ដែលសាវ័កសំដែង ។

៣-ឥសិភាសិត ធម៌ដែលឥសីសំដែង ។

៤-ទេវតាភាសិត ធម៌ដែលទេវតាសំដែង ។

## ខណៈដែលបុគ្គលគួរប្រាថ្នា ៤ យ៉ាង

១-ពុទ្ធុប្បាទក្ខណោ ខណៈដែលមានព្រះពុទ្ធត្រាស់ ។

២-មជ្ឈិមប្បទេសេ ឧបត្តិក្ខណោ ខណៈដែលបានកើតក្នុងមជ្ឈិមប្រទេស ។

៣-សម្មាទិដ្ឋិយា បដិលទ្ធក្ខណោ ខណៈដែលបានជាសម្មាទិដ្ឋិ ។

៤-ឆន្នមាយតនានំ អវេកលក្ខណោ ខណៈដែលមានអាយតនទាំងប្រាំមួយមិនវិកលខ្វះខាត ។

## អត្ថនៃអភិធម្ម ៤ យ៉ាង

១- ចិត្ត ២-ចេតសិក ៣- រូប ៤- និព្វាន

## ចិត្ត ៤ ប្រការ

១- កាមាវចរចិត្ត ២- រូបាវចរចិត្ត

៣- អរូបាវចរចិត្ត ៤- លោកុត្តរចិត្ត

## អធិដ្ឋានធម៌ "ធម៌ដែលគួរតាំងទុកក្នុងចិត្ត" ៤ យ៉ាង

**១-បញ្ញា** សេចក្តីដឹងសព្វ ។

**២-សច្ច** សេចក្តីពិត ។

**៣-ចាគ** ការលះ ។

**៤-ឧបសម** ស្ងប់ចិត្ត ។

## អធិបតី ៤ យ៉ាង

**១-ឆន្ទ** បំណងក្នុងចិត្ត ។

**២-វីរិយ** សេចក្តីព្យាយាម ។

**៣-ចិត្ត** សេចក្តីគិត ។

**៤-វីមំសា** សេចក្តីពិចារណា ។

## ការរកបានដោយក្រ ៤ យ៉ាង

**១-កិច្ឆោ មនុស្សប្បដិលាភោ** កម្រនឹងបានកើតជាមនុស្ស ។

**២-កិច្ឆំ មច្ចាន ជីវិតំ**

កម្រនឹងចិញ្ចឹមជីវិតដោយស្រួលរបស់ពួកសត្វ

**៣-កិច្ឆំ សទ្ធម្មស្សវនំ** កម្រនឹងបានស្តាប់ព្រះសទ្ធម្ម ។

**៤-កិច្ឆោ ពុទ្ធានំ ឧប្បាទោ** កម្រនឹងបានត្រាស់ជាព្រះពុទ្ធ ។

## បញ្ចកៈ ពួកធម៌ប្រាំ

## រតន ៥ យ៉ាង

**១-**ការកើតឡើងនៃព្រះសម្មាសម្ពុទ្ធ ។

**២-**បុគ្គលអ្នកសំដែងធម៌វិន័យ ។

**៣-**បុគ្គលអ្នកចេះធម៌វិន័យ ។

**៤-**បុគ្គលអ្នកប្រតិបត្តិនូវធម៌សមគួរដល់ធម៌ ។

**៥-**បុគ្គលជាកតញ្ញូកតវេទី ។

## ព្រះពុទ្ធទ្រង់សម្រេចកិច្ចដោយកាល ៥

**១-បុព្វណ្ហេ បិណ្ឌបាតំ** ទ្រង់បិណ្ឌបាតក្នុងវេលាព្រឹក ។

**២-សាយណ្ហេ ធម្មទេសនំ** ទ្រង់សំដែងធម៌ក្នុងវេលាល្ងាច ។

**៣-បទោសេ ភិក្ខុ ឱវាទំ** ទ្រង់ប្រទានឱវាទដល់ភិក្ខុក្នុងវេលាព្រលប់ ។

**៤-អឌ្ឍរត្តេ ទេវបញ្ហនំ** ទ្រង់ដោះប្រស្នាទេវតាក្នុងវេលាអធ្រាត្រ

**៥-បច្ចូសេវ គតេ កាលេ ភព្វាភព្វេ វិលោកនំ** ទ្រង់ពិចារណាមើលឧបនិស្ស័យសត្វដែលគួរត្រាស់ដឹង នឹងមិនគួរត្រាស់ដឹងក្នុងវេលាបែកបច្ចូស(ជិតភ្លឺ) ។

## អនុបុព្វីកថា ៥ យ៉ាង

**១-ទានកថា** សំដែងអំពីទាន ។

**២-សីលកថា** សំដែងអំពីសីល ។

**៣-សគ្គកថា** សំដែងអំពីស្ថានសួគ៌ ។

**៤-កាមាទីនវកថា** សំដែងអំពីទោសកាម ។

**៥-នេក្ខម្មានិសំសកថា** សំដែងអំពីអានិសង្សនៃការចេញចាកកាម ឬ ការចេញបួស ។

## កាលទាន ៥ យ៉ាង

**១-អាគន្តុកទាន** ឱ្យទានដល់អ្នកដែលទើបនឹងមកដល់ថ្មី ។

**២-គមិកទាន** ឱ្យទានដល់អ្នកដែលរៀបចំដំណើរនឹងចេញទៅ ។

**៣-គិលានទាន** ឱ្យទានដល់អ្នកមានជម្ងឺ ។

**៤-ទុព្ភិក្ខទាន** ឱ្យទានក្នុងវេលាទុរ្ភិក្ស ។

**៥-នវទាន** ឱ្យទានផ្លែឈើ ឬ អ្វីដែលទើបនឹងមានដំបូង ។

## សប្បុរិសទាន ៥ យ៉ាង

**១-សទ្ធាយ ទានំ ទេតិ** ឱ្យទានដោយសទ្ធា ។

**២-សក្កច្ចំ ទានំ ទេតិ** ឱ្យទានដោយគោរព ។

**៣-កាលេន ទានំ ទេតិ** ឱ្យទានតាមកាលគួរ ។

**៤-អនុគ្គហិតចិត្តោ ទានំ ទេតិ** ឱ្យទានដោយតាំងចិត្តអនុគ្រោះ ។

**៥-អត្តានញ្ច បរញ្ច អនុបហច្ច ទានំ ទេតិ** ឱ្យទានមិនបៀតបៀន ខ្លួនឯងនឹងអ្នកដទៃ ។

## សប្បុរិសទាន ៥ យ៉ាង

**១-សក្កច្ចំ ទានំ** ឱ្យទានដោយគោរពចំពោះទេយ្យវត្ថុ ។

**២-ចិត្តីកត្វា ទេតិ** ឱ្យទានធ្វើសេចក្តីគោរពចំពោះវត្ថុ និងបដិគ្គាហក ។

**៣-សហត្ថា ទេតិ** ឱ្យទានដោយដៃខ្លួនឯង ។

**៤-អនុបវិដ្ឋំ ទេតិ** ឱ្យទានដោយមិនបានបោះអោយ ។

**៥-អាគមនទិដ្ឋិកោ ទេតិ** ឱ្យទានដោយសេចក្តីជឿថានឹងបាន ទទួលផលពុំខាន ។

## អសប្បុរិសទាន ៥ យ៉ាង

**១-អសក្កច្ចំ ទេតិ** ឱ្យដោយឥតមានសេចក្តីគោរពចំពោះទេយ្យវត្ថុ

**២-អចិត្តីកត្វា ទេតិ** ឱ្យទានដោយឥតមានសេចក្តីគោរពចំពោះ ទេយ្យវត្ថុនិងបដិគ្គាហក ។

**៣-អសហត្ថា ទេតិ** មិនឱ្យដោយដៃខ្លួនឯង ។

**៤-អបវិដ្ឋំ ទេតិ** ឱ្យទានដូចគេបោះចោល ។

**៥-អនាគមនទិដ្ឋិកោ ទេតិ** ឱ្យទានដោយចិត្តជឿថានឹងមិនបាន ទទួលផល ។

## ទានឥតផល ៥ យ៉ាង

**១-ឥត្ថីទានំ** ឱ្យស្ត្រីជាទានដល់បុរស ។

**២-ឧសភទានំ** ឱ្យគោឈ្មោលដល់គោញី ។

**៣-មជ្ជទាន** ឱ្យទានទឹកស្រវឹង ។

**៤-សមជ្ជទានំ** អោយទានរបាំល្បែងមហោស្រព ។

**៥-ចិត្តកម្មទាន** ឱ្យទានគំនូរគូររូបស្រីនិងប្រុស ដែលជាគំនូរនាំឱ្យ កើតកាមរាគ ។

**អានិសង្សទាន ៥ យ៉ាង**

**១-ពហុជនស្ស បិយោ ហោតិ**
ជាទីស្រឡាញ់រាប់អាននៃជនច្រើន។

**២-សន្តោ សប្បុរិសោ ភជន្តិ** ពួកសប្បុរសរមែងចូលចិត្ត រាប់រក។

**៣-កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** មានកេរ្តិ៍ឈ្មោះពិរោះល្បី ល្បាញទៅគ្រប់ទិស ។

**៤-វិសារទោ ឧបសង្កមតិ** ក្លៀវក្លាចូលទៅទីប្រជុំជន ។

**៥-កាយស្ស ភេទា បរម្មរណា សុគតិំ ឧបបជ្ជតិ**
លុះបែកធ្លាយរាង កាយបន្ទាប់អំពីសេចក្តីស្លាប់ បានទៅកើតក្នុងសុគតិ ។

**ប្រយោជន៍របស់ភោគ ៥ យ៉ាង**

**១-** ចិញ្ចឹមខ្លួន,មាតាបិតា,បុត្រភរិយា,បាវព្រាវអោយជាសុខ ។

**២-** ចិញ្ចឹមពួកញាតិមិត្រអោយជាសុខ ។

**៣-** បំបាត់អន្តរាយ ដែលកើតអំពីហេតុផ្សេងៗ ។

**៤-** ធ្វើបលី ៥ យ៉ាង ។

**៥-** បរិច្ចាគទាន ដល់សមណព្រាហ្មណ៍ អ្នកប្រតិបត្តិត្រូវ ។

**ពលី ៥ យ៉ាង**

**១-ញាតិពលី** សង្គ្រោះញាតិ ។

**២-អតិថិពលី** ទទួលភ្ញៀវ ។

**៣-បុព្វបេតពលី** ធ្វើបុណ្យឧទ្ទិសផល ឱ្យអ្នកដែលចែកស្ថាន ទៅហើយ ។

**៤-រាជពលី** បង់ពន្ធដារជូនរាជការ ។

**៥-ទេវតាពលី** ធ្វើបុណ្យឧទ្ទិសផលដល់ពពួកទេវតា ។

**គតិ ៥ យ៉ាង**

១-នរក, ២-តិរច្ឆាន, ៣-បេតវិស័យ, ៤-មនុស្ស, ៥-ទេវតា ។

**មច្ឆរិយ** "សេចក្តីកំណាញ់" **៥ យ៉ាង**

**១-អាវាសមច្ឆរិយ** កំណាញ់អាវាស ។

**២-កុលមច្ឆរិយ** កំណាញ់ត្រកូល ។

**៣-លាភមច្ឆរិយ** កំណាញ់លាភ ។

**៤-វណ្ណមច្ឆរិយ** កំណាញ់ពណ៌សម្បុរ ឬកំណាញ់សេចក្តីសរសើរ

**៥-ធម្មមច្ឆរិយ** កំណាញ់ធម៌ ។

**គារវៈ ៥ យ៉ាង ជាហេតុញុំាងព្រះសទ្ធម្មឱ្យឋិតនៅបានយូរ**

**១-សត្ថរិ គារវោ** គោរពចំពោះព្រះសាស្តា ។

**២-ធម្មេ គារវោ** គោរពចំពោះព្រះធម៌ ។

៣-**សង្ឃេ គារវោ** គោរពចំពោះព្រះសង្ឃ ។

៤-**សិក្ខាយ គារវោ** គោរពចំពោះសិក្ខា ។

៥-**សមាធិស្មឹ គារវោ** គោរពចំពោះសមាធិ ។

**ធម៌ ៥ យ៉ាង ដែលអាចធ្វើបុគ្គលឱ្យតាំងនៅមាំក្នុងព្រះសទ្ធម្ម**

១-**សទ្ធា** ជឿហេតុដែលគួរជឿ ។

២-**ហិរិ** ខ្មាស់បាបខ្មាស់ទុច្ចរិត ។

៣-**អារោគ្យសម្បទា** បរិបូណ៌ដោយភាពជាអ្នកឥតមានរោគ ។

៤-**សីលសម្បទា** បរិបូណ៌ដោយសីល ។

៥-**ទិដ្ឋិសម្បទា** បរិបូណ៌ដោយទិដ្ឋិ ។

**សំវរវិន័យ ៥ យ៉ាង**

១-**សីលសំវរ** សង្រួមក្នុងបាដិមោក្ខ ។

២-**សតិសំវរ** សង្រួមក្នុងចក្ខុន្ទ្រិយ ។

៣-**ញាណសំវរ** សង្រួមក្នុងខ្សែតណ្ហាដោយបញ្ញា ។

៤-**ខន្តិសំវរ** សង្រួមក្នុងខន្តី គឺ អត់ធន់នូវត្រជាក់និងក្តៅជាដើម ។

៥-**វីរិយសំវរ** សង្រួមក្នុងវិរិយៈ គឺ កំចាត់បង់នូវវិតក្កៈ ៣ យ៉ាង មានកាមវិតក្កៈជាដើម ។

**បហានវិន័យ ៥ យ៉ាង**

១-**តទង្គប្បហាន** លះកិលេសដោយអង្គនោះៗ មានកិរិយាកំណត់ដឹងនូវកាមនឹងរូបដោយវិបស្សនាញាណជាដើម ។

២-**វិក្ខម្ភនប្បហាន** លះកិលេសមាននីវរណធម៌ជាដើមដោយសមាធិ

៣-**សមុច្ឆេទប្បហាន** លះកិលេសដាច់ស្រេចក្នុងខណៈ ដែលបាននូវអរិយមគ្គទាំង ៤ ប្រការ ។

៤-**បដិបស្សទ្ធិប្បហាន** លះកិលេសដាច់ស្រេចក្នុងខណៈដែលបាននូវអរិយផល ។

៥-**និស្សរណប្បហាន** លះកិលេសជ្រះស្រឡះ គឺបាននៅព្រះនិព្វាន

**អានិសង្សរបស់ខន្តី ៥ យ៉ាង**

១-**បិយោ មនាបោ** ជាទីស្រឡាញ់ពេញចិត្តនៃជនច្រើន ។

២-**នវេរពហុលោ** មិនច្រើនដោយពៀរ ។

៣-**នវជ្ជពហុលោ** មិនច្រើនដោយទោស ។

៤-**អសម្មូឡ្ហោ** មិនវង្វេងក្នុងមរណសម័យ ។

៥-**សុគតិ** កាលទំលាយខ្លួនរមែងទៅកាន់សុគតិភព ។

**វេសារជ្ជករណធម៌** "ធម៌ដែលធ្វើឱ្យមានសេចក្តីក្លាហាន" **៥ យ៉ាង**

១-**សទ្ធា** ជឿហេតុដែលគួរជឿ ។

២-**សីល** រក្សាកាយវាចាអោយរៀបរយ ។

៣-**ពាហុសច្ច** ភាពជាអ្នកស្តាប់ច្រើនរៀនសូត្រច្រើន ។

៤-**វីរិយារម្ភ** ប្រារព្ធព្យាយាម ។

**៥-បញ្ញា** ដឹងនូវហេតុដែលគួរដឹង ។

**ពល"កម្លាំង" ៥ យ៉ាង**

**១-សទ្ធា** ជំនឿ ។

**២-វីរិយ** ព្យាយាម ។

**៣-សតិ** សេចក្ដីរឭក ។

**៤-សមាធិ** ការតាំងចិត្ត ។

**៥-បញ្ញា** ដឹងសព្វ ។

(ធម៌ទាំង ៥ យ៉ាងនេះហៅថា"ឥន្ទ្រិយ"ក៏បាន)

**វិបត្តិនៃឧបាសក ៥ យ៉ាង**

**១-អស្សទ្ធោ ហោតិ** មិនជឿគុណព្រះរតនត្រ័យ ។

**២-ទុស្សីលោ ហោតិ** ទ្រុស្តសីល ។

**៣-កោតូហលមង្គលិកោហោតិ** ប្រកបដោយមង្គលភ្ញាក់ផ្អើល ។

**៤-មង្គលំ បច្ចេតិ នោ កម្មំ** ប្រកាន់ជឿមង្គល មិនជឿកម្មនឹងផល នៃកម្ម ។

**៥-ឥតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ច បុព្វការំ ករោតិ** ស្វែងរកទក្ខិណេយ្យបុគ្គល ក្រៅព្រះពុទ្ធសាសនាហើយធ្វើទានចំពោះទក្ខិណេយ្យបុគ្គលនោះ ។

**សម្បត្តិនៃឧបាសក ៥ យ៉ាង**

**១-សទ្ធោ ហោតិ** ជឿគុណព្រះរតនត្រ័យ ។

**២-សីលវាហោតិ** មានសីល ។

**៣-ន កោតូហលមង្គលិកោ ហោតិ** មិនប្រកបដោយមង្គលភ្ញាក់ផ្អើល ។

**៤-កម្មំ បច្ចេតិ នោ មង្គលំ** ជឿតែកម្មមិនជឿមង្គល ។

**៥-ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ ឥធ ច បុព្វការំ ករោតិ** មិនស្វែងរកទក្ខិណេយ្យបុគ្គលក្រៅព្រះពុទ្ធសាសនាឡើយ ហើយធ្វើទានចំពោះតែទក្ខិណេយ្យបុគ្គល ក្នុងព្រះពុទ្ធសាសនា ។

**ជំនួញដែលឧបាសកមិនគួរធ្វើ ៥ យ៉ាង**

**១-សត្ថវណិជ្ជា** ជួញគ្រឿងសស្ត្រាវុធ ។

**២-សត្តវណិជ្ជា** ជួញសត្វមានជីវិត ។

**៣-មំសវណិជ្ជា** ជួញសាច់ ។

**៤-មជ្ជវណិជ្ជា** ជួញទឹកស្រវឹង ។

**៥-វិសវណិជ្ជា** ជួញថ្នាំពិស ។

**ទោសនៃសីលវិបត្តិរបស់អ្នកទ្រុស្តសីល ៥ យ៉ាង**

**១-បមាទាធិករណំ មហតី ភោគជានី និគច្ឆតិ** តែងដល់នូវសេចក្ដីវិនាសសម្បត្តិយ៉ាងធំ ដោយមានសេចក្ដីបមាទជាហេតុ ។

**២-បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** កិត្តិសព្ទអាក្រក់រមែងផ្សាយទៅសព្វទិស ។

**៣-អវិសារទោ ឧបសង្កមតិ** ចូលទៅកាន់ទីប្រជុំបរិស័ទណា ។

ឥតមានសេចក្តីក្លៀវក្លា ។
៤-សម្មូឡ្ហោ កាលំ ករោតិ តែងវង្វេងធ្វើមរណកាល ។
៥-កាយស្ស ភេទា បរម្មរណា ទុគ្គតិ ឧបបជ្ជតិ
លុះបែកធ្លាយរាង កាយបន្ទាប់អំពីសេចក្តីស្លាប់
តែងទៅកើតទុគ្គតិ ។

**អានិសង្សសីលសម្បទារបស់អ្នកមានសីល ៥ យ៉ាង**

១-អប្បមាទាធិករណំ មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ តែងបានភោគសម្ប័ទ ដោយមានសេចក្តីមិនប្រមាទជាហេតុ ។
២-កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ កិត្តិសព្ទដ៏ពិរោះតែងផ្សាយទៅសព្វទិស ។
៣-វិសារទោ ឧបសង្កមតិ ចូលទៅកាន់ទីប្រជុំបរិសទ្ធណា ៗ តែង មានសេចក្តីក្លៀវក្លា ។
៤-អសម្មូឡ្ហោ កាលំ ករោតិ តែងមិនវង្វេងធ្វើមរណកាល ។
៥-កាយស្ស ភេទា បរម្មរណា សុគតី ឧបបជ្ជតិ
លុះបែងធ្លាយរាង កាយបន្ទប់អំពីសេចក្ត
ស្លាប់តែងទៅកើតក្នុងសុគ្គតិ ។

**បុគ្គលប្រកបដោយធម៌ ៥ យ៉ាង នឹងទៅកាន់នរក**

១-អស្សទ្ធោ មិនមានសទ្ធា ។
២-អហិរិកោ មិនមានហិរិ ។
៣-អនោត្តប្បី មិនមានឧត្តប្បៈ ។
៤-កុសីតោ ខ្ជិលច្រអូស ។
៥-ទុប្បញ្ញោ ឥតប្រាជ្ញា ។
(ធម៌ ៥ យ៉ាងនេះអាចធ្វើមិនឱ្យបុគ្គលឋិតនៅក្នុងព្រះសទ្ធម្ម)

**បុគ្គលប្រកបដោយធម៌ ៥ យ៉ាង នឹងទៅកើតក្នុងស្ថានសួគ៌**

១-សទ្ធោ មានសទ្ធា ។
២-ហិរិមា មានហិរិ ។
៣-ឱត្តប្បី មានឱត្តប្បៈ ។
៤-អារទ្ធវីរិយោ មានព្យាយាម ។
៥-បញ្ញវា មានប្រាជ្ញា ។
(ធម៌ ៥ យ៉ាងនេះអាចធ្វើបុគ្គលឱ្យឋិតនៅក្នុងព្រះសទ្ធម្ម)

**កំលាំងរបស់ព្រះពុទ្ធ ៥ យ៉ាង**

១-សទ្ធាពល កម្លាំងសទ្ធា ។
២-ហិរិពល កម្លាំងហិរិ ។
៣-ឱត្តប្បពល កម្លាំងឱត្តប្បៈ ។
៤-វីរិយពល កម្លាំងព្យាយាម ។
៥-បញ្ញាពល កម្លាំងបញ្ញា ។

**សេចក្តីមិនសង្រួមបណ្តាលអោយកើតកិលេស ៥ យ៉ាង**

១-អស្សទ្ធា មិនមានជំនឿ ។
២-អក្ខន្តី មិនមានសេចក្តីងអត់ធន់ ។

៣-**គោសជ្ជំ** សេចក្តីខ្ជិលច្រអូស ។
៤-**មុដ្ឋសច្ចំ** សេចក្តីភ្លេចស្មារតី ។
៥-**អញ្ញាណំ** សេចក្តីល្ងង់ ។

**អនន្តរិយកម្ម ៥ យ៉ាង**

១-**មាតុឃាដ** សម្លាប់មាតា ។
២-**បិតុឃាដ** សម្លាប់បិតា ។
៣-**អរហន្តឃាដ** សម្លាប់ព្រះអរហន្ត ។
៤-**លោហិតុប្បាទ** ធ្វើព្រះលោហិតរបស់ព្រះពុទ្ធ ឱ្យពុះពងដោរ ដោយចិត្តប្រទូស្តនឹងព្រះអង្គ ។
៥-**សង្ឃភេទ** បំបែកសង្ឃ ។

**សង្ឃភេទ**"ការបំបែកសង្ឃ"**ដោយហេតុ ៥ យ៉ាង**

១-**កម្មេន** ដោយសង្ឃកម្ម ។
២-**ឧទ្ទេសេន** ដោយឧទ្ទេស ។
៣-**វោហរន្តា** ដោយពោលភេទករណវត្ថុ ១៨ ប្រការ ។
៤-**អនុសាវនេន** ដោយពោលល្បួងលួងលោម ឱ្យភិក្ខុដ៏ទៃជឿកាន់តាមលទ្ធិរបស់ខ្លួន ។
៥-**សលាកគ្គាហេន** ដោយសរសេរស្លាកអោយចាប់ ។

**អន្តរធាន ៥ យ៉ាង**

១-**បរិយត្តិអន្តរធាន** សាបសូន្យបរិយត្តិ ។
២-**បដិបត្តិអន្តរធាន** សាបសូន្យការប្រតិបត្តិ ។
៣-**បដិវេធអន្តរធាន** សាបសូន្យការត្រាស់ដឹង ។
៤-**លិង្គអន្តរធាន** សាបសូន្យភេទសមណ ។
៥-**ធាតុអន្តរធាន** សាបសូន្យព្រះបរមសារីរិកធាតុ ។

**ទោសនៃបុគ្គលប្រព្រឹត្តទុច្ចរិត ៥ យ៉ាង**

១-**អត្តាបិ អត្តានំ ឧបវទតិ** សូម្បីខ្លួនឯងក៏តិះដៀលខ្លួនឯង ។
២-**អនុវិច្ច វិញ្ញូ គរហន្តិ** អ្នកប្រាជ្ញទាំងឡាយក៏រមែងតិះដៀល។
៣-**បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** កិត្តិសព្ទអាក្រក់ក៏ផ្សាយខ្ចរខ្ចាយ ។
៤-**សម្មូឡ្ហោ កាលំ ករោតិ** វង្វេងធ្វើមរណកាល ។
៥-**អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ** នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាក នរក ។

**អានិសង្សនៃបុគ្គលប្រព្រឹត្តសុចរិត ៥ យ៉ាង**

១-**អត្តាបិ អត្តានំ ន ឧបវទតិ** សូម្បីខ្លួនឯងក៏តិះដៀលខ្លួងឯងមិនបាន ។
២-**អនុវិច្ច វិញ្ញូ បសំសន្តិ** អ្នកប្រាជ្ញទាំងឡាយរមែងសរសើរ ។
៣-**កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ** កិត្តិសព្ទពិរោះក៏ផ្សាយចេញ ។
៤-**អសម្មូឡ្ហោ កាលំ ករោតិ** មិនវង្វេងធ្វើមរណកាល ។

**៥-សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ** នឹងទៅកើតក្នុងសុគតិ គឺស្ថាន សួគ៌នឹងមនុស្សលោក ។

### អន្តរាយិកធម៌ "ធម៌ធ្វើអោយអន្តរាយ" ៥ យ៉ាង

**១-កម្មន្តរាយ** អន្តរាយព្រោះកម្មបានដល់អនន្តរិយកម្ម ៥ យ៉ាង ។

**២-កិលេសន្តរាយ** អន្តរាយព្រោះកិលេសបានដល់និយតមិច្ឆាទិដ្ឋិ ។

**៣-វិបាកន្តរាយ** អន្តរាយព្រោះវិបាក បានដល់បដិសន្ធិធម៌នៃពួក បណ្ឌក,តិរច្ឆាន,ឧភតោព្យញ្ជនក ។

**៤-ឧបវាទន្តរាយ** អន្តរាយព្រោះឧបវាទ បានដល់អរិយបវាទ ។

**៥-អាណាវិតិក្កមន្តរាយ** អន្តរាយព្រោះអាណាវិតក្កមទោស បានដល់ អាបត្តិដែលភិក្ខុត្រូវ ព្រោះតាំងចិត្តក្លែង ។

### នីវរណៈ ៥

**១-កាមច្ឆន្ទ** សេចក្តីពេញចិត្តក្នុងកាម ។

**២-ព្យាបាទ** សេចក្តីគំគួន ចង់ធ្វើគេអោយវិនាស ។

**៣-ថីនមិទ្ធ** សេចក្តីងោកងក់ច្រុលជ្រប់ក្នុងចិត្ត ។

**៤-ឧទ្ធច្ចកុក្កុច្ច** សេចក្តីរសាប់រសល់រាយមាយក្នុងចិត្ត ។

**៥-វិចិកិច្ឆា** សេចក្តីឆ្ងល់សង្ស័យ ។

### ទីកើតនីវរណៈ ៥

**១-កាមច្ឆន្ទ** កើតអំពីសុភនិមិត្ត គឺកំណត់អារម្មណ៍ថាល្អ ។

**២-ព្យាបាទ** កើតអំពីបដិឃនិមិត្តគឺកំណត់ក្នុងការចង្អៀតចង្អល់ចិត្ត



**៣-ថីនមិទ្ធ** កើតអំពីអរតិ គឺសេចក្តីមិនត្រេកអរ និងសេចក្តីខ្ជិល ប្រមទាំងការស្រវឹងក្នុងអាហារ ។

**៤-ឧទ្ធច្ចកុក្កុច្ច** កើតអំពីចេតសោអវូបសមគឺសេចក្តីមិនស្ងប់នៃ ចិត្ត ។

**៥-វិចិកិច្ឆា** កើតអំពីអយោនិសោមនសិការ គឺមិនធ្វើទុកក្នុងចិត្ត ដោយឧបាយប្រាជ្ញា ។

### ខន្ធ ៥ យ៉ាង

១. **រូប**, ២. **វេទនា**, ៣. **សញ្ញា**, ៤. **សង្ខារ**, ៥. **វិញ្ញាណ**,

### ឧបមានៃខន្ធ ៥

**១-ផេណបិណ្ឌូបមំ រូបំ** រូបប្រៀបដូចពពុះទឹក ។

**២-វេទនាបុព្វុឡូបមា** វេទនាប្រៀបដូចក្រពេញទឹក ។

**៣-មរីចិកូបមា សញ្ញា** សញ្ញាប្រៀបដូចថ្ងៃបណ្តើរកូន ។

**៤-សង្ខារា កទលូបមា** សង្ខារប្រៀបដូចដើមចេក ។

**៥-មាយូបមញ្ច វិញ្ញាណំ** វិញ្ញាណប្រៀបដូចកលមាយា ។

**ទេសិតា និច្ចពន្ធុនា** សេចក្តីឧបមានេះ ព្រះសម្មាសម្ពុទ្ធជាផៅ ពង្សនៃព្រះអាទិត្យសំដែងហើយ ។

### សល្ល "ធម៌ដូចជាព្រួញ" ៥ យ៉ាង

១_ រាគៈ, ២_ ទោសៈ, ៣_ មោហៈ, ៤_ មានៈ, ៥_ ទិដ្ឋិ,

### ចេតោខីល "បង្គោលដែលបោះជាប់ក្នុងចិត្ត" ៥ យ៉ាង

១-សត្ថរិ កង្ខតិ សង្ស័យក្នុងព្រះសាស្ដា ។

២-ធម្មេ កង្ខតិ សង្ស័យក្នុងព្រះធម៌ ។

៣-សង្ឃេ កង្ខតិ សង្ស័យក្នុងព្រះសង្ឃ ។

៤-សិក្ខាយ កង្ខតិ សង្ស័យក្នុងសិក្ខា ។

៥-សព្រហ្មចារីសុ កុប្បិតោ ហោតិ មានចិត្តក្រេវក្រោធទៅរកសព្រហ្មចារីបុគ្គលទាំងឡាយ ។

### លំអររបស់ស្ត្រី ៥ យ៉ាង

១-ឆវិកល្យាណ លំអសម្បុរស្បែក ។

២-មំសកល្យាណ លំអសាច់ ។

៣-កេសកល្យាណ លំអសក់ ។

៤-អដ្ឋិកល្យាណ លំអធ្មេញទាំង ៣២ ។

៥-វយកល្យាណ លំអវ័យ ។

### ហេតុនាំអោយអាយុខ្លី ៥ យ៉ាង

១-អសប្បាយការី មិនធ្វើខ្លួនឱ្យសប្បាយ ។

២-សប្បាយេ មត្តំ នជានាតិ មិនដឹងប្រមាណក្នុងការសប្បាយ ។

៣-អបរិណតភោជិ

បរិភោគអាហារភ្លើងធាតុធ្វើឱ្យរលាយមិនទាន់។

៤-អកាលចារិ ដើរលេងខុសកាល ។

៥-អព្រហ្មចារី ប្រព្រឹត្តធម៌មិនប្រសើរ(ល្មោភក្នុងកាម) ។

### ហេតុដែលនាំអោយអាយុវែង ៥ យ៉ាង

១-សប្បាយការី ធ្វើខ្លួនអោយសប្បាយ ។

២-សប្បាយេ មត្តំ ជានាតិ ដឹងប្រមាណក្នុងការសប្បាយ ។

៣-បរិណតភោជី បរិភោគអាហារ ល្មមភ្លើងធាតុឱ្យរលាយទន់ស្រួល ។

៤-កាលចារី ដើរលេងក្នុងកាលគួរ ។

៥-ព្រហ្មចារី ប្រព្រឹត្តធម៌ដ៏ប្រសើរ(មិនល្មោភកាម) ។

### អង្គឈាន ៥ យ៉ាង

១-វិតក្ក ការត្រិះរិះរំពឹងអារម្មណ៍ ។

២-វិចារ ការពិចារណាអារម្មណ៍ ។

៣-បីតិ សេចក្ដីឆ្អែតកាយឆ្អែតចិត្ត ។

៤-សុខ សេចក្ដីសប្បាយកាយសប្បាយចិត្ត ។

៥-ឯកគ្គតា មានអារម្មណ៍នឹងតែមួយ ។

### អង្គឈានជាបដិបក្ខនឹងនីវរណៈ ៥ យ៉ាង

១-សមាធិ កាមច្ឆន្ទស្ស បដិបក្ខោ សមាធិជាបដិបក្ខនឹងកាមច្ឆន្ទ។

២-បីតិ ព្យាបាទស្ស បដិបក្ខោ បីតិជាបដិបក្ខ និង ព្យាបាទ ។

៣-វិតក្កោ ថីនមិទ្ធស្ស បដិបក្ខោ វិតក្កៈជាបដិបក្ខ និងថីនមិទ្ធ។

**៤-សុខំ ឧទ្ធច្ចកុក្កុច្ចស្ស បដិបក្ខោ** សុខជាបដិបក្ខ និងឧទ្ធច្ចកុក្កុច្ច

**៥-វិចារោ វិចិកិច្ឆាយ បដិបក្ខោ** វិចារៈជាបដិបក្ខ និងវិចិកិច្ឆា។

### បីតិ ៥ យ៉ាង

**១-ខុទ្ទកា បីតិ** មានលក្ខណៈឱ្យព្រឺរោមព្រឺស្បែក ។

**២-ខណិកា បីតិ** មានលក្ខណដូចផ្លេកបន្ទោរប្រាកដក្នុងចក្ខុ ។

**៣-ឱក្កន្តិកា បីតិ** មានលក្ខណៈឱ្យកាយញ័រកក្រើកដូចរលកទឹក ។

**៤-ឧព្វេគា បីតិ** មានលក្ខណៈធ្វើឱ្យកាយស្រាលអណ្ដែតឡើង ។

**៥-ផរណា បីតិ** មានលក្ខណៈផ្សាយសព្វកាយ ។

### វសី"ការស្ទាត់" ៥ យ៉ាង

**១-អាវជ្ជនវសី** ស្ទាត់ក្នុងការនឹកអង្គឈាន ។

**២-សមាបជ្ជនវសី** ស្ទាត់ក្នុងការចូលឈាន ។

**៣-អធិដ្ឋានវសី**
ស្ទាត់ក្នុងការអធិដ្ឋានដើម្បីរក្សាឈានទុកឱ្យមាំមួន។

**៤-វុដ្ឋានវសី** ស្ទាត់ក្នុងការចេញចាកឈាន ។

**៥-បច្ចវេក្ខណវសី** ស្ទាត់ក្នុងការពិចារណាអង្គឈាន ក្នុងវេលាដែលចេញចាកឈាន ។

### សប្បាយ ៥ យ៉ាង

**១-អាវាសសប្បាយ** សប្បាយដោយទីនៅ ។

**២-ឧតុសប្បាយ** សប្បាយដោយរដូវ ។

**៣-អាហារសប្បាយ** សប្បាយដោយភោជនាហារ ។

**៤-បុគ្គលសប្បាយ** សប្បាយដោយបុគ្គល ។

**៥-ធម្មស្សវនសប្បាយ** សប្បាយដោយការស្ដាប់ធម៌ ។

### ធម៌ជាគ្រឿងធ្វើវិមុត្តិឱ្យចាស់ក្លា ៥ យ៉ាង

**១-កល្យាណមិត្តតា** ភាពជាអ្នកមានមិត្តល្អ ។

**២-សីលសម្បទា** បរិបូណ៌ដោយសីល ។

**៣-អភិសល្លេខកថា** ពោលពាក្យដ៏ផូរផង់ប្រកបដោយកថាវត្ថុ ១0យ៉ាង ។

**៤-វីរិយារម្ភ** ប្រារព្ធព្យាយាម ។

**៥-បញ្ញាសម្បទា** បរិបូណ៌ដោយប្រាជ្ញា ។

### សញ្ញាជាគ្រឿងធ្វើវិមុត្តិឱ្យចាស់ក្លា ៥ យ៉ាង

**១-អនិច្ចសញ្ញា** សចេក្ដីសំគាល់ថាមិនទៀង ។

**២-អនិច្ចេ ទុក្ខសញ្ញា** សេចក្ដីសំគាល់ថាជាទុក្ខក្នុងធម៌មិនទៀង។

**៣-ទុក្ខេ អនត្តសញ្ញា** សេចក្ដីសំគាល់ថាមិនមែនរបស់ខ្លួនក្នុងធម៌ប្រកបដោយទុក្ខ ។

**៤-បហានសញ្ញា** សេចក្ដីសំគាល់ក្នុងធម៌ជាគ្រឿងលះបង់ ។

**៥-វិរាគសញ្ញា** សេចក្ដីសំគាល់ក្នុងធម៌ជាគ្រឿងនឿយណាយ ។

### អនិមិត្តក"ធម៌ដែលកំណត់មិនបាន" ៥ យ៉ាង

១-ជីវិត ការរស់នៅ ។
២-ព្យាធិ ការឈឺចាប់ ។
៣-កាល ពេលវេលា ។
៤-ទេហនិក្ខេបន ការដាក់ចុះនូវរាងកាយ(សេចក្ដីស្លាប់) ។
៥-គតិ ដំណើរដែលនឹងកើតក្នុងសុគតិ ឬទុគ្គតិ ។

**ទេវទូត ៥ យ៉ាង**

១-ទារក ក្មេងតូចដែលទើបសម្រាល ។
២-ជរា ចាស់គ្រាំគ្រានៃខន្ធ ។
៣-ព្យាធិ ជម្ងឺដំកាត់ ។
៤-ទណ្ឌ អ្នកទោស ។
៥-មរណ សេចក្ដីស្លាប់ ។

**មារ ៥ យ៉ាង**

១-ខន្ធមារ មារ គឺខន្ធ ។
២-កិលេសមារ មារ គឺកិលេស ។
៣-អភិសង្ខារមារ មារ គឺអភិសង្ខារ ។
៤-ទេវបុត្តមារ មារ គឺទេវបុត្រ ។
៥-មច្ចុមារ មារ គឺសេចក្ដីស្លាប់ ។

**អលព្ភនីយដ្ឋាន"ហេតុដែលមិនគួរចង់បាន" ៥ យ៉ាង**

១-ជរា ចាស់គ្រាំគ្រា ។
២-ព្យាធិ ជម្ងឺដំកាត់ ។
៣-មរណ សេចក្ដីស្លាប់ ។
៤-នស្សន សេចក្ដីវិនាស ។
៥-ខយ សេចក្ដីសាបសូន្យ,ការអស់ទៅ ។

**អភិណ្ហប្បច្ចវេក្ខណ"ធម៌សម្រាប់ពិចារណារឿយៗ" ៥ យ៉ាង**

១-ជរា ពិចារណាពីជរា ។
២-ព្យាធិ ពិចារណាពីព្យាធិ ។
៣-មរណ ពិចារណាពីមរណៈ ។
៤-វិយោគ ពិចារណាពីការព្រាត់ប្រាស់ ។
៥-កម្ម ពិចារណាពីអំពើកម្ម ដែលខ្លួនបានធ្វើ ។

**បុច្ឆា"ពាក្យសួរ" ៥ យ៉ាង**

១-អទិដ្ឋជោតនា បុច្ឆា ពាក្យសួរ ជាគ្រឿងបំភ្លឺនូវសេចក្ដីដែលខ្លួនមិនដែលឃើញ ។
២-ទិដ្ឋសំសន្ទនា បុច្ឆា ពាក្យសួរ ជាគ្រឿងសន្ទនាគ្នាចំពោះប្រស្នាដែលធ្លាប់ឃើញ ។
៣-វិមតិច្ឆេទនា បុច្ឆា ពាក្យសួរ ជាគ្រឿងកាត់បង់នូវសេចក្ដីសង្ស័យ ។
៤-អនុមតិ បុច្ឆា ពាក្យសួរតាមសេចក្ដីយល់ឃើញរបស់ខ្លួន(ពាក្យសួរចាក់បណ្ដោយ) ។

**៥-អថេត្វតម្បិតា បុច្ឆា**

ពាក្យសួរប្រាថ្នានឹងឆ្លើយខ្លួនឯង(សួរខ្លួនឯង ឆ្លើយខ្លួនឯង) ។

**មហាបរិចាគ ៥ យ៉ាង**

**១-អង្គបរិច្ចាគ** បរិច្ចាគសរីរាងអវៈយវៈជាទាន ។

**២-ធនបរិច្ចាគ** បរិច្ចាគទ្រព្យជាទាន ។

**៣-បុត្តបរិច្ចាគ** បរិច្ចាគបុត្រជាទាន ។

**៤-ទារបរិច្ចាគ** បរិច្ចាគភរិយាជាទាន ។

**៥-ជីវិតបរិច្ចាគ** បរិច្ចាគជីវិតជាទាន ។

**វត្ថុដែលទេវទត្តសូម ៥ យ៉ាង**

១- សូមឱ្យពួកភិក្ខុនៅក្នុងព្រៃអស់មួយជីវិត ។

២- សូមឱ្យពួកភិក្ខុប្រព្រឹត្តបិណ្ឌបាតអស់មួយជីវិត ។

៣- សូមឱ្យពួកភិក្ខុប្រើប្រាស់តែសំពត់បំសុកូលអស់មួយជីវិត ។

៤- សូមឱ្យពួកភិក្ខុនៅតែក្នុងម្លប់ឈើអស់មួយជីវិត ។

៥- សូមកុំឱ្យពួកភិក្ខុឆាន់ត្រីនិងសាច់អស់មួយជីវិត ។

(សេចក្តីសូមទាំង ៥
យ៉ាងនេះព្រះពុទ្ធជាម្ចាស់មិនអនុញ្ញាតឡើយ)

**ធម្មតារបស់គហបតី ៥ យ៉ាង**

**១-ភោគាធិប្បាយា** ប្រាថ្នាភោគសម្បទ ។

**២-បញ្ញូបចារា** ចូលចិត្តត្រិះរិះខាងផ្លូវប្រាថ្នា ។

**៣-សិប្បាធិដ្ឋានា** តាំងចិត្តចំពោះទៅរកសិល្បសាស្ត្រ ។

**៤-កម្មន្តាភិនិវេសា** ប្រកាន់ចិត្តមាំក្នុងការងារ ។

**៥-និដ្ឋិតកម្មន្តបរិយោសានា** មានការងារហើយស្រេចជាទីបំផុត។

**ធម្មតារបស់ចោរ ៥ យ៉ាង**

**១-អាទានាធិប្បាយា** ចូលចិត្តតែក្នុងការលួចទ្រព្យរបស់អ្នកដទៃ។

**២-គហណូបចារា** ត្រិះរិះក្នុងការលួចទ្រព្យរបស់អ្នកដទៃ ។

**៣-សត្ថាធិដ្ឋានា** តាំងចិត្តស្វែងរកគ្រឿងសស្ត្រាវុធ ។

**៤-អន្ធការាភិនិវេសា** ពេញចិត្តក្នុងទីងងឹត ។

**៥-អទស្សនបរិយោសានា** មិនចង់ឱ្យគេឃើញជាទីបំផុត(មិនចង់ឱ្យគេឃើញខ្លួនសោះ) ។

**ធម្មតារបស់សមណៈ ៥ យ៉ាង**

**១-ខន្តិសោរច្ចាធិប្បាយា** មានប្រាថ្នាតែក្នុងខន្តីនឹងសោរច្ចៈ ។

**២-បញ្ញូបចារា** ចូលចិត្តត្រិះរិះខាងផ្លូវប្រាជ្ញា ។

**៣-សីលាធិដ្ឋានា** តាំងចិត្តមាំក្នុងសីល ។

**៤-អកិញ្ចនាភិនិវេសា** ពេញចិត្តក្នុងការមិនមានកង្វល់ ។

**៥-និព្វានបរិយោសានា** មានព្រះនិព្វានជាទីបំផុត ។

**កូនត្រូវប្រតិបត្តិមាតាបិតាដោយស្ថាន ៥ យ៉ាង**

**១-ភរណៈ** ការចិញ្ចឹមមាតាបិតា ។

**២-កិច្ចករណៈ** ការធ្វើកិច្ចការជំនួសមាតាបិតា ។

**៣-កុលវំសំ ឋបេន្តិ** ការដំកល់វង្សត្រកូលមាតាបិតាទុកឱ្យល្អមិនឱ្យវិនាស ។

**៤-ទាយជ្ជារមាបដិបជ្ជន** ការប្រតិបត្តិមាតាបិតាឱ្យសមគួរដល់ការទទួលសម្បត្តិមត៌ក ។

**៥-ទក្ខិណានុប្បទាន** ការធ្វើទក្ខិណាទានឧទ្ទិសផលជូនទៅមាតាបិតារឿយ ៗ ។

### មាតាបិតាត្រូវអនុគ្រោះកូនដោយស្ថាន ៥ យ៉ាង

**១-បាបា និវារេន្តិ** ហាមឃាត់កូនមិនឱ្យធ្វើបាប ។

**២-កល្យាណេ និវេសេន្តិ** ឱ្យកូនតាំងនៅក្នុងកម្មជាកុសល ។

**៣-សិប្បំ សិក្ខាបេន្តិ** ឱ្យកូនសិក្សារៀនសិល្បសាស្ត្រ ។

**៤-បដិរូបេន ទារេន សំយោជេន្តិ** រៀបចំឱ្យកូនមានភរិយា ឬស្វាមីតាមសមគួរដល់ជាតិ ត្រកូល និងទ្រព្យសម្បត្តិ ។

**៥-សមយេ ទាយជ្ជំ និយ្យាទេន្តិ** ឱ្យទ្រព្យសម្បត្តិដល់កូនក្នុងសម័យ ដែលគួរអោយ ។

### សិស្សត្រូវប្រតិបត្តិគ្រូអាចារ្យដោយស្ថាន ៥ យ៉ាង

**១-ឧដ្ឋានេន** ដោយធ្វើបច្ចុគ្គមនាការ និងអនុគ្គមនាការ ។

**២-បច្ចុបដ្ឋានេន** ដោយចូលទៅបំរើតាមកាល ។

**៣-សុស្សូសាយ** ដោយជឿស្តាប់ពាក្យឱវាទគ្រូអាចារ្យ ។

**៤-បារិចរិយាយ** ដោយការបំរើបន្តិចបន្តួច(មិនកំណត់ពេល) ។

**៥-សក្កច្ចំ សិប្បុគ្គហណេន** ដោយការរៀនសិល្បសាស្ត្រដោយគោរព ។

### គ្រូអាចារ្យត្រូវអនុគ្រោះសិស្សដោយស្ថាន ៥ យ៉ាង

**១-សុវិនីតំ វិនេន្តិ** ទូន្មានប្រៀនប្រដៅសិស្សដោយល្អ ។

**២-សុគ្គហិតំ អាហាបេន្តិ** បង្ហាត់បង្រៀនសិស្សដោយល្អ ។

**៣-សព្វសិប្បេសុ តំ សមក្ខា យិនោ ភវន្តិ** បង្ហាត់បង្រៀនសិស្សគ្រប់សិល្បសាស្ត្រចំពោះវិជ្ជាដែលខ្លួនចេះ ។

**៤-មិត្តាមច្ចេសុ បដិវេទេន្តិ** សំដែងគុណសម្បត្តិសិស្សក្នុងកណ្តាលជំនុំមិត្រនិងអាមាត្យ ។

**៥-ទិសាសុ បរិត្តាណំ ករោន្តិ** ធ្វើនូវសេចក្តីការពាររក្សាសិស្សសព្វទិស ។

### ស្វាមីត្រូវអនុគ្រោះភរិយាដោយស្ថាន ៥ យ៉ាង

**១-សម្មាននាយ** ដោយសេចក្តីរាប់អានដោយសំដីដ៏ទន់ផ្អែម ។

**២-អវិមាននាយ** ដោយការមិនបៀតបៀនមើលងាយ ។

**៣-អនតិចរិយាយ** ដោយការមិនប្រព្រឹត្តកន្លងចិត្តភរិយា ។

**៤-ឥស្សរិយវោស្សគ្គេន** ដោយការប្រគល់ឱ្យនូវឥស្សរិយស ។

**៥-អលង្ការានុប្បទានេន** ដោយការផ្គត់ផ្គង់នូវគ្រឿងប្រដាប់ដល់ភរិយា ។

### ភរិយាត្រូវប្រតិបត្តិស្វាមីដោយស្ថាន ៥ យ៉ាង

១-សុសំវិហិតកម្មន្តា ចាត់ចែងការងារដោយផ្ចិតផ្ចង់ ។
២-សុសង្គហិតបរិជនា សង្គ្រោះដល់ញាតិរបស់ស្វាមីនិងញាតិរបស់ខ្លួនដោយស្មោះស្មើ ។
៣-សម្ភតញ្ច អនុរក្ខតិ ចេះថែទាំទុកដាក់ទ្រព្យសម្បត្តិដែលស្វាមីរកបានមកហើយ ។
៤-អនតិចារិនី មិនប្រព្រឹត្តកន្លងចិត្តស្វាមី ។
៥-ទក្ខា ច ហោតិ អនលសា សព្វកិច្ចេសុ ឆ្លាសប្រសប់ប្រមទាំងមិនខ្ជិលច្រអូសក្នុងកិច្ចការគ្រប់យ៉ាង ។

**កុលបុត្រត្រូវទំនុកបំរុងមិត្រសម្លាញ់ដោយស្ថាន ៥ យ៉ាង**

១-ទានេន ដោយឱ្យទ្រព្យរបស់ដែលគួរអោយ ។
២-បិយវជ្ជេន ដោយពោលពាក្យដ៏ពិរោះ ។
៣-អត្ថចរិយាយ ដោយប្រព្រឹត្តធ្វើនូវប្រយោជន៍ឱ្យដល់មិត្រ ។
៤-សមានត្តតាយ ដោយភាពជាអ្នកមានចិត្តស្មើដោយមិត្រ ។
៥-អវិសំវាទនតាយ ដោយមិនក្លែងពោលពាក្យកុហក ។

**មិត្តសម្លាញ់ត្រូវអនុគ្រោះកុលបុត្រដោយស្ថាន ៥ យ៉ាង**

១-បមត្តំ រក្ខន្តិ ជួយរក្សាកុលបុត្រដែលភ្លាត់ភ្លាំងធ្វេសប្រហែស។
២-បមត្តស្ស សាបតេយ្យំ រក្ខន្តិ ជួយថែរក្សាទ្រព្យសម្បត្តរបស់កុល បុត្រដែលភ្លាត់ភ្លាំងធ្វេសប្រហែស ។
៣-ភីតស្ស សរណំ ហោន្តិ អាចធ្វើជាទីពឹងកុលបុត្រដែលមានសេចក្តីភិតភ័យ ។
៤-អាបទាសុ ន ជហន្តិ មិនលះបង់ចោលគ្នាក្នុងកាលមានភ័យ។
៥-អបរប្បជំ បិស្ស បដិបូជេន្តិ ស្រឡាញ់រាប់អានកូនចៅផៅពង្សត្រកូលរបស់កុលបុត្រ ។

**ចៅហ្វាយនាយត្រូវទំនុកបំរុងទាសកម្មករដោយស្ថាន ៥ យ៉ាង**

១-យថាពលំ កម្មន្ត សំវិធានេន ដោយចាត់ចែងការងារឱ្យធ្វើតាមសមគួរដល់កម្លាំង ។
២-ភត្តវេត្តនានុប្បទានេន ដោយឱ្យនូវភត្តាហារនឹងថ្លៃឈ្នួល ។
៣-គិលានុបដ្ឋានេន ដោយព្យាបាលរក្សាក្នុងកាលមានជម្ងឺ ។
៤-អច្ឆរិយានំ រសានំ សំវិភាគេន ដោយចែករំលែកនូវរបស់ដែលមានរសឆ្ងាញ់ពិសា ។
៥-សមយេ វោស្សគ្គេន ដោយបើកឱកាសឱ្យឈប់ធ្វើការក្នុងសម័យដែលគួរឱ្យឈប់សម្រាក ។

**ទាសកម្មករត្រូវយកចិត្តទុកដាក់នឹងចៅហ្វាយដោយស្ថាន ៥យ៉ាង**

១-បុព្វុដ្ឋាយិនោ ក្រោកឡើងធ្វើការងារមុនចៅហ្វាយជាដ៏រាប ។
២-បច្ឆានិបាតិនោ ឈប់ធ្វើការក្រោយចៅហ្វាយនាយជាដរាប ។
៣-ទិន្នាទាយិនោ យកតែទ្រព្យរបស់ដែលចៅហ្វាយឱ្យជាដរាប ។
៤-សុកតកម្មការកា ធ្វើការដោយពិនិត្យពិច័យអស់ពិចិត្ត ។

**៥-កិត្តិវណ្ណហារា** នាំកិត្តគុណរបស់ចៅហ្វាយនាយទៅពោលសរសើរក្នុងទីទាំងពួង ។

**កុលបុត្រជាគ្រហស្ថត្រូវប្រតិបត្តិសមណព្រាហ្មណ៍ដោយស្ថាន ៥យ៉ាង**

**១-មេត្តេន កាយកម្មេន** ដោយកាយកម្មប្រកបដោយមេត្តា ។

**២-មេត្តេន វចីកម្មេន** ដោយវចីកម្មប្រកបដោយមេត្តា ។

**៣-មេត្តេន មនោកម្មេន** ដោយមនោកម្មប្រកបដោយមេត្តា ។

**៤-អនាវដទ្វារតាយ** ដោយមិនបិទទ្វារផ្ទះរបស់ខ្លួន ។

**៥-អមិសានុប្បទានេន** ដោយអោយនូវអាមិស ។

**សមណព្រាហ្មណ៍ត្រូវអនុគ្រោះកុលបុត្រដោយស្ថាន ៦យ៉ាង**

**១-បាបា និវារេន្តិ** ហាមឃាត់កុលបុត្រមិនឱ្យធ្វើបាប ។

**២-កល្យាណេ និវេសេន្តិ** ឱ្យកុលបុត្រដំកល់នៅក្នុងការកុសល ។

**៣-កល្យាណេន មនសា អនុកម្បន្តិ** អនុគ្រោះកុលបុត្រដោយកល្យាណចិត្ត ។

**៤-អស្សុតំ សាវេន្តិ** ឱ្យកុលបុត្រស្តាប់ធម៌ដែលមិនធ្លាប់បានស្តាប់។

**៥-សុតំ បរិយោទបេន្តិ** ញុំាងធម៌ដែលកុលបុត្រធ្លាប់ស្តាប់ហើយឱ្យផូរ ផង់ល្អ ។

**៦-សគ្គស្ស មគ្គំ អាចិក្ខន្តិ** ប្រាប់ផ្លូវសួគ៌ដល់កុលបុត្រ ។

(ធម៌ពួក ៦ ដែលនាំយកមកចារិកក្នុងពួក៥នេះ ព្រោះនឹងបំបែកឱ្យឆ្ងាយពីគ្នា មិនសមតាមទំនងដែលទាក់ទងរកគ្នា)

**ឆក្ក ពួកធម៌ប្រាំមួយ**

**ទិស ៦**

**១-មាតាបិតា ទិសាបុព្វា** ទិសខាងកើត ទុកជាមាតាបិតា ។

**២-អាចរិយា ទក្ខិណាទិសា** ទិសខាងត្បូង ទុកជាអាចារ្យ ។

**៣-បុត្តទារា ទិសាបច្ឆា** ទិសខាងលិច ទុកជាបុត្រភរិយា ។

**៤-មិត្តាមច្ចា ច ឧត្តរា** ទិសខាងជើង ទុកជាមិត្រសំឡាញ់ ។

**៥-ទាសកម្មករា ហេដ្ឋា** ទិសខាងក្រោម ទុកជាទាសកម្មករ ។

**៦-ឧទ្ធំសមណព្រាហ្មណា** ទិសខាងលើ ទុកជាសមណព្រាហ្មណ៍។

**គ្រូ ៦**

**១**-បូរណកស្សប, **២**-មក្ខលិគោសាល, **៣**-និគ្គណ្ឋនាដបុត្រ, **៤**-សញ្ជយវេលដ្ឋបុត្រ, **៥**-បកុធកចាយនៈ, **៦**-អជិតកេសកម្ពល, ។ (គ្រូទាំង ៦ នេះជាសត្រូវនឹងព្រះពុទ្ធសាសនា)

**គុណសម្បត្តិនៃបុគ្គលជានាយលើគេ ៦ យ៉ាង**

**១-ខមា** មានសេចក្តីអត់ធន់ ។

**២-ជាគរិយ** មានសេចក្តីភ្ញាក់ឮករឿយៗ(វាងវៃ) ។

**៣-ឧដ្ឋាន** មានសេចក្តីឧស្សាហ៍ព្យាយាម ។

**៤-សំវិភាគ** មានការចែករំលែក ។

**៥-ទយា** មានសេចក្តីងាណិតអាសូរ ។

**៦-ឥក្ខនា** មានការពិនិត្យត្រួតត្រាពិចារណា ។

## **វិបត្តិ ៦ យ៉ាង**

**១-គតិវិបត្តិ** ខុសគតិ គឺកើតក្នុងអបាយភូមិទាំង ៤ ណាមួយ ។

**២-កាលវិបត្តិ** ខុសកាល គឺកើតឡើងក្នុងគ្រាដែលមិនមានព្រះពុទ្ធ សាសនា ។

**៣-ទេសវិបត្តិ** ខុសប្រទេស គឺប្រទេសដែលមិនមានព្រះពុទ្ធសាសនា

**៤-កុលវិបត្តិ** ខុសត្រកូល គឺត្រកូលដែលមិនមានសទ្ធាជ្រះថ្លាក្នុង ព្រះពុទ្ធសាសនា ។

**៥-ឧបធិវិបត្តិ** ខុសរាងកាយ គឺរាងកាយវិកលវិការ ។

**៦-ទិដ្ឋិវិបត្តិ** ខុសទិដ្ឋិ គឺជាមិច្ឆាទិដ្ឋិ ។

## **សម្បត្តិ ៦ យ៉ាង**

**១-គតិសម្បត្តិ** ដល់ប្រមដោយគតិ គឺបានកើតជាមនុស្ស ។

**២-កាលសម្បត្តិ** ដល់ប្រមដោយកាល គឺបានកើតក្នុងគ្រាដែលមាន ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។

**៣-ទេសសម្បត្តិ** ដល់ព្រមដោយប្រទេសគឺប្រទេសដែលមានព្រះពុទ្ធ សាសនា ។

**៤-កុលសម្បត្តិ** ដល់ព្រមដោយត្រកូលគឺត្រកូលដែលជ្រះថ្លាក្នុងព្រះ ពុទ្ធសាសនា ។

**៥-ឧបធិសម្បត្តិ** ដល់ព្រមដោយរាងកាយគឺរាងកាយមិនវិកលវិការ។

**៦-ទិដ្ឋិសម្បត្តិ** ដល់ព្រមដោយទិដ្ឋិ គឺសម្មាទិដ្ឋិ ។

## **អបាយមុខ**“ប្រធាននៃសេចក្តីវិនាស” **៦ យ៉ាង**

១-ប្រព្រឹត្តផឹកទឹកស្រវឹង គឺសុរាមេរ័យ ។

២-ប្រព្រឹត្តដើរលេងតាមច្រកល្ហកក្នុងវេលាយប់ ។

៣-ប្រព្រឹត្តដើរមើលល្បែងមហោស្រព ។

៤-ប្រព្រឹត្តលេងល្បែងភ្នាល់ ។

៥-សេពគប់នឹងបាបមិត្រ ។

៦-ខ្ជិលច្រអូសក្នុងកិច្ចការទាំងពួង ។

## ទោសផឹងសុរា ៦ យ៉ាង

**១-សន្ទិដ្ឋិកា ធនជានិ** នាំឱ្យវិនាសទ្រព្យនឹងឃើញច្បាស់ទាន់ភ្នែក

**២-កលហប្បវឌ្ឍនី** នាំឱ្យចំរើនខាងការឈ្លោះប្រកែច ។

**៣-រោគានំ អាយតនំ** ជាហេតុនាំឱ្យកើតរោគច្រើនយ៉ាង ។

**៤-អកិត្តិសញ្ជននី** បណ្តាលឱ្យខូចកេរ្តិ៍ឈ្មោះឬឱ្យកើតគរហានន្ទា

**៥-ហិរិកោបិនទំសនី** នាំឱ្យលេចកេរ្តិ៍ខ្មាស ។

**៦-បញ្ញាយ ទុព្វលីករណី** ធ្វើប្រាជ្ញាឱ្យមានកំលាំងថយ(នាំឱ្យ ខ្សោយប្រាជ្ញា ។

## ទោសដើរលេងយប់ ៦ យ៉ាង

១-អត្តាបិស្ស អគុត្តោ អរក្ខិតោ ហោតិ ជាអ្នកមិនស្ងួនគ្រងរក្សាខ្លួន ។

២-បុត្តទារោបិស្ស អគុត្តា អរក្ខិតោ ហោតិ ជាអ្នកមិនគ្រប់គ្រងរក្សាបុត្រភរិយា ។

៣-សាបតេយ្យំបិស្ស អគុត្តំ អរក្ខិតោ ហោតិ ជាអ្នកមិនគ្រប់គ្រងទ្រព្យសម្បត្តិ ។

៤-សំកិយោ ច ហោតិ នាំអោយគេរង្កៀស ។

៥-អភូតវចនញ្ច តស្មឹ រូហតិ

ពាក្យមិនពិតរមែងកើតឡើងដល់អ្នក ដើរលេងយប់នោះ ។

៦-ពហូនញ្ច ទុក្ខធម្មានំ បុរក្ខតោ ហោតិ រមែងប្រកបដោយទុក្ខទោសច្រើនយ៉ាង ។

## ទោសដើរមើលល្បែង ៦ យ៉ាង

១-ក្វ នច្ចំ មានល្បែងរាំក្នុងទីណា ដើរទៅក្នុងទីនោះ ។

២-ក្វ គីតំ មានចំរៀងក្នុងទីណា ដើរទៅក្នុងទីនោះ ។

៣-ក្វ វាទិតំ មានល្បែងដេញដំប្រគំក្នុងទីណា ដើរទៅក្នុងទីនោះ។

៤-ក្វ អក្ខានំ មានគេប្រជុំនិយាយរឿងព្រេងឥតប្រយោជន៍ក្នុងទី ណា ដើរទៅក្នុងទីនោះ ។

៥-ក្វ បាណិស្សរំ មានល្បែងច្រៀងទះដៃក្នុងទីណា ដើរទៅក្នុងទីនោះ ។

៦-ក្វ កុម្ភថូណំ មានសូរសព្ទភ្លេងតូរ្យតន្ត្រី មានស្គររនាតគងជាដើមក្នុងទីណា ដើរទៅក្នុងទីនោះ ។

## ទោសលេងល្បែងភ្នាល់ ៦ យ៉ាង

១-ជយំ យំ បសវតិ អ្នកលេងឈ្លូងរមែងធ្វើឱ្យអ្នកចាញ់ចងវេរា។

២-ជិនោ ចិត្តមនុសោចតិ អ្នកលេងចាញ់រមែងសោកស្តាយទ្រព្យដែលវិនាសទៅ ។

៣-សន្ទិដ្ឋិកា ធនជានិ សេចក្តីវិនាសទ្រព្យនឹងឃើញច្បាស់ទាន់ភ្នែក ។

៤-សភាគតស្ស វចនំ នរូហតិ ពាក្យរបស់អ្នកលេងល្បែងភ្នាល់នឹងយកជាសាក្សី ជាបន្ទាល់ពិតមិនបាន ។

៥-មិត្តាមច្ចានំ បរិភូតោ ហោតិ ពួកមិត្រសំឡាញ់ដែលគេមិនលេងល្បែងភ្នាល់ តែងមើលងាយ ។

៦-អាវាហវិវាហកានំ អបត្ថិតោ ហោតិ ពួកជនអ្នកធ្វើនូវអាវាហាវិវាហមង្គល គេមិនត្រូវការឡើយ ។

## ទោសសេពគប់មិត្រអាក្រក់ ៦ យ៉ាង

១-យេ ធុត្តា មិត្រឯណា ជាអ្នកលេងល្បែងភ្នាល់ ។

២-យេ សោណ្ឌា មិត្រឯណា ជាអ្នកលេងស្រី ។

៣-**យេ បិបាសា** មិត្រឯណា ជាអ្នកលេងផឹកសុរា ។

៤-**យេ នេតតិតា** មិត្រឯណា ជាអ្នកបញ្ឆោតបោកប្រាសអ្នកដទៃដោយរបស់ក្លែង ។

៥-**យេ ឧញ្ចនិតា** មិត្រឯណា

ជាអ្នកប្រវ័ញ្ចន៍បញ្ឆោតអ្នកដទៃក្នុងទី ចំពោះមុខ ។

៦-**យេ សាហសិតា មិត្រឯណា** ជាអ្នកលួចលាក់ឆក់ដណ្តើមយកទ្រព្យរបស់អ្នកដទៃ ។

(ទោសកើតឡើងតាមការសេពគប់នឹងមិត្រនោះ ៗ)

**ទោសនៃសេចក្តីខ្ជិលច្រអូស ៦ យ៉ាង**

១-**អតិសីតំ** មិនធ្វើការងារដោយអាងថាត្រជាក់ណាស់រងាណាស់ ។

២-**អតិឧណ្ហំ** មិនធ្វើការងារដោយអាងថា ក្តៅណាស់ ។

៣-**អតិសាយំ** មិនធ្វើការងារដោយអាងថា ល្ងាចណាស់ ។

៤-**អតិបាតោ** មិនធ្វើការងារដោយអាងថា នៅព្រឹកណាស់ ។

៥-**អតិឆាតោ** មិនធ្វើការងារដោយអាងថា ឃ្លានណាស់ ។

៦-**អតិបិបាសិតោ** មិនធ្វើការងារដោយអាងថា ស្រេកណាស់ ។

**ផ្លូវនៃសេចក្តីអាត្រគត់ ៦ យ៉ាង**

១-**អាលស្យ** សេចក្តីខ្ជិលច្រអូស ។

២-**បមាទ** សេចក្តីធ្វេសប្រហែស ។

៣-**អនុដ្ឋាន** មិនមានព្យាយាម ។

៤-**អសញ្ញម** មិនប្រយ័ត្ន ។

៥-**និទ្ទា** ការដេកលក់ ។

៦-**អនតរតិ** មិនត្រេកអរក្នុងធម៌វិន័យ ។

**សារាណីយធម៌ ៦ យ៉ាង**

១-**មេត្តា កាយកម្ម** ធ្វើអ្វីដោយកាយប្រកបដោយមេត្តា ។

២-**មេត្តា វចីកម្ម** ធ្វើអ្វីដោយវាចាប្រកបដោយមេត្តា ។

៣-**មេត្តា មនោកម្ម** ធ្វើអ្វីដោយចិត្តប្រកបដោយមេត្តា ។

៤-**លាភ** ចែកលាភដែលបានដោយធម៌ដល់មិត្រសព្រហ្មចារី ។

៥-**សីល** រក្សាសីលល្អស្មើគ្នានឹងមិត្រសព្រហ្មចារី ។

៦-**ទិដ្ឋិ** សេចក្តីយល់ត្រូវស្មើគ្នានឹងមិត្រសព្រហ្មចារី ។

**គារវៈ ៦ យ៉ាង**

១-**ពុទ្ធគារវតា** គោរពព្រះពុទ្ធ ។

២-**ធម្មគារវតា** គោរពព្រះធម៌ ។

៣-**សង្ឃគារវតា** គោរពព្រះសង្ឃ ។

៤-**សិក្ខាគារវតា** គោរពសិក្ខា ។

៥-**អប្បមាទគារវតា** គោរពអប្បមាទធម៌ ។

៦-**បដិសណ្ឋារគារវតា** គោរពបដិសណ្ឋារៈ ។

**ហាយនភាគិយធម៌** "ធម៌ជាចំណែកនៃសេចក្តីវិនាស" **៦ យ៉ាង**

១-សត្ថរិ អគារវោ មិនគោរពព្រះសាស្តា ។

២-ធម្មេ អគារវោ មិនគោរពព្រះធម៌ ។

៣-សង្ឃេ អគារវោ មិនគោរពព្រះសង្ឃ ។

៤-សិក្ខាយ អគារវោ មិនគោរពសិក្ខា ។

៥-អប្បមាទេ អគារវោ មិនគោរពអប្បមាទធម៌ ។

៦-បដិសណ្ឋារេ អគារវោ មិនគោរពបដិសណ្ឋារ ។

**អនុស្សតិ ៦ យ៉ាង**

១-ពុទ្ធានុស្សតិ រឭកដល់គុណព្រះពុទ្ធ ។

២-ធម្មានុស្សតិ រឭកដល់គុណព្រះធម៌ ។

៣-សង្ឃានុស្សតិ រឭកដល់គុណព្រះសង្ឃ ។

៤-សីលានុស្សតិ រឭកដល់សីលដែលខ្លួនរក្សា ។

៥-ចាគានុស្សតិ រឭកដល់ទានដែលខ្លួនបានបរិច្ចាគហើយ ។

៦-ទេវតានុស្សតិ

រឭកដល់គុណធម៌ដែលធ្វើបុគ្គលឱ្យរក្សាជាទេវតា។

**អនុត្តរិយ "កិច្ចដ៏ប្រសើរ" ៦ យ៉ាង**

១-ទស្សនានុត្តរិយ ការឃើញប្រសើរ ។

២-សវនានុត្តរិយ ការស្តាប់ប្រសើរ ។

៣-លាភានុត្តរិយ ការបានប្រសើរ ។

៤-សិក្ខានុត្តរិយ ការសិក្សាប្រសើរ ។

៥-បារិចរិយានុត្តរិយ ការបំរើប្រសើរ ។

៦-អនុស្សតានុត្តរិយ ការរឭកប្រសើរ ។

**អគោចរ "ទីមិនគួរទៅ" ៦ យ៉ាង**

១-វេសិយាគោចរ ទីមិនគួរទៅ គឺទីស្រីពេស្យា ។

២-វិធវាគោចរ ទីមិនគួរទៅ គឺទីស្រីមេមាយ ។

៣-ថុល្លកុមារីគោចរ ទិមិនគួរទៅ គឺទីស្រីក្រចាស់ ។

៤-ភិក្ខុនីគោចរ ទីមិនគួរទៅ គឺទីនាងភិក្ខុនី ។

៥-បណ្ឌកគោចរ ទីមិនគួរទៅ គឺទីបណ្ឌក ។

៦-បានាគារគោចរ ទីមិនគួរទៅ គឺរោងផឹកសុរា ។

**សីល ៦ របស់នាងសិក្ខមានា**

១-វៀរចាកបាណាតិបាត ។

២-វៀរចាកអទិន្នាទាន ។

៣-វៀរចាកអព្រហ្មចរិយ ។

៤-វៀរចាកមុសាវាទ ។

៥-វៀរចាកសុរាមេរ័យ ។

៦-វៀរចាកវិកាលភោជន ។

**កាមាវចរសួគ៌ ៦ យ៉ាង**

១-ចាតុម្មហារាជិក, ២-តាវត្តឹស, ៣-យាមា, ៤-តុសិត,

៥-និម្មានរតី, ៦-បរនិម្មិតវសវត្តី, ។

## ចរិត “ការប្រព្រឹត្ត” ៦

១-**រាគចរិត** ការប្រព្រឹត្ត ច្រើនដោយរាគៈ ។

២-**ទោសចរិត** ការប្រព្រឹត្ត ច្រើនដោយទោស ។

៣-**មោហចរិត** ការប្រព្រឹត្ត ច្រើនដោយមោហៈ ។

៤-**វិតក្កចរិត** ការប្រព្រឹត្ត ច្រើនដោយវិតក្កៈ ។

៥-**សទ្ធាចរិត** ការប្រព្រឹត្ត ច្រើនដោយសទ្ធា ។

៦-**ពុទ្ធិចរិត** ការប្រព្រឹត្ត ច្រើនដោយប្រាជ្ញា ។

## តណ្ហាគោចរ ៦

១-**រូបតណ្ហា** តណ្ហាអាស្រ័យរូប ។

២-**សទ្ទតណ្ហា** តណ្ហាអាស្រ័យសំឡេង ។

៣-**គន្ធតណ្ហា** តណ្ហាអាស្រ័យក្លិន ។

៤-**រសតណ្ហា** តណ្ហាអាស្រ័យរស ។

៥-**ផោដ្ឋព្វតណ្ហា** តណ្ហាអាស្រ័យការពាល់ត្រូវដោយកាយ ។

៦-**ធម្មតណ្ហា** តណ្ហាអាស្រ័យអារម្មណ៍ដែលដឹងដោយចិត្ត ។

(តាំង ៦ នេះហៅថា **មហាគព្ធធម៌** “ធម៌គួរលះបង់” ក៏បាន)

## វិធីលះកាមច្ឆន្ទ ៦ យ៉ាង

១-**អសុភនិមិត្តស្ស ឧគ្គហោ** រៀននូវសុភនិមិត្ត ។

២-**អសុភភាវនា នុយោគោ** ព្យាយាមចំរើនអសុភភាវនា ។

៣-**ឥន្ទ្រិយេសុ គុត្តទ្វារតា** រក្សាទ្វារក្នុងឥន្ទ្រិយទាំង ៦ ។

៤-**ភោជនេ មត្តញ្ញុតា** ដឹងប្រមាណដោយបរិភោគ ។

៥-**កល្យាណមិត្តតា** មានកល្យាណមិត្រ ។

៦-**សប្បាយកថា** ពោលពាក្យជាទីសប្បាយ គឺនិយាយតាមទំនង នៃកថាវត្ថុ ១០ យ៉ាង ។

## វិធីលះព្យាបាទ ៦ យ៉ាង

១-**មេត្តានិមិត្តស្ស ឧគ្គហោ** រៀននូវមេត្តានិមិត្ត ។

២-**មេត្តាភាវនានុយោគោ** ព្យាយាមចំរើនមេត្តាភាវនា ។

៣-**កម្មស្សកតា បច្ចវេក្ខណា** ពិចារណាឃើញថាសត្វមានកម្ម របស់ខ្លួន ។

៤-**បដិសង្ខានពហុលតា** ច្រើនដោយការពិចារណា ។

៥-**កល្យាណមិត្តតា** មានកល្យាណមិត្រ ។

៦-**សប្បាយកថា** ពោលពាក្យជាទីសប្បាយ ។

## វិធីលះថីនមិទ្ធ ៦ យ៉ាង

១-**អតិភោជនេ និមិត្តគ្គាហោ** រៀនកំណត់ក្នុងការបរិភោគច្រើន។

២-**ឥរិយាបថសម្បវិវត្តនតា** ផ្លាស់ប្ដូរនូវឥរិយាបថ ។

៣-**អាលោកសញ្ញាមនសិការោ** ធ្វើទុកក្នុងចិត្តចំពោះអាលោក សញ្ញា។

៤-**អព្ភោកាសវាសោ** នៅក្នុងទីវាលស្រឡះ ។

៥-**កល្យាណមិត្តតា** មានកល្យាណមិត្រ ។

៦-សប្បាយកថា ពោលពាក្យជាទីសប្បាយ ។

**វិធីលះឧទ្ធច្ចកុក្កុច្ច ៦ យ៉ាង**

១-ពហុស្សុតតា រៀនច្រើន ស្ដាប់ច្រើន ។

២-បរិបុច្ឆកតា ឧស្សាហ៍សាកសួរ ។

៣-វិនយេ បកតញ្ញុតា ចេះស្ទាត់ក្នុងវិន័យ ។

៤-វុឌ្ឍសេវិតា សេពគប់នឹងលោកចាស់ប្រឹទ្ធាចារ្យ ។

៥-កល្យាណមិត្តតា មានកល្យាណមិត្រ ។

៦-សប្បាយកថា ពោលពាក្យជាទីសប្បាយ ។

**វិធីលះវិចិកិច្ឆា ៦ យ៉ាង**

១-ពហុស្សុតតា រៀនច្រើន ស្ដាប់ច្រើន ។

២-បរិបុច្ឆកតា ឧស្សាហ៍សាកសួរ ។

៣-វិនយេ បកតញ្ញុតា ចេះស្ទាត់ក្នុងវិន័យ ។

៤-អធិមោក្ខពហុលតា ច្រើនដោយការចេះដឹងប្រាកដ ។

៥-កល្យាណមិត្តតា មានកល្យាណមិត្រ ។

៦-សប្បាយកថា ពោលពាក្យជាទីសប្បាយ ។

**បុគ្គលមិនគួរដល់នូវគុណ ៦ យ៉ាង**

១-បាបិច្ឆោ អ្នកមានបំណងអាក្រក់ ។

២-ឥស្សាបកតោ អ្នកមានចិត្តច្រណែនឈ្នានីស ។

៣-កុហកោ អ្នកកុហក ។

៤-ខិលចិត្តោ អ្នកឃើញតែពោះខ្លួនឬគិតត្រឹមតែពោះខ្លួន ។

៥-លាភកាមោ អ្នកប្រាថ្នាលាភ ។

៦-ហេតុកាមោ អ្នកមានបំណងឱ្យគេសរសើរខ្លួន ។

**ទោសរបស់រាគៈទោសៈមោហៈ ៦ យ៉ាង**

១-អន្ធករណោ ធ្វើឱ្យងងឹតងងល់ ។

២-អចក្ខុករណោ ធ្វើមិនឱ្យមានចក្ខុឃើញធម៌ពិត ។

៣-អញ្ញាណករណោ ធ្វើមិនឱ្យមានញាណដឹងធម៌ពិត ។

៤-វិឃាតបក្ខិក ធ្វើឱ្យប្រព្រឹត្តទៅក្នុងពួកនៃសេចក្ដីចង្អៀតចង្អល់ចិត្ត ។

៥-បញ្ញានិរោធក ធ្វើឱ្យរលត់ប្រាជ្ញា ។

៦-អនិព្វានសំវត្តនិក ធ្វើមិនអោយប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។

**អាយតនៈខាងក្នុង ៦**

១ ចក្ខុ ភ្នែក, ២ សោត ត្រចៀក, ៣ ឃាន ច្រមុះ,

៤ ជិវ្ហា អណ្ដាត, ៥ កាយ កាយ, ៦ មន ចិត្ត,

**អាយតនៈ ខាងក្រៅ ៦**

១ រូប រូប, ២ សទ្ទ សំឡេង, ៣ គន្ធ ក្លិន, ៤ រស រស,

៥ ផោដ្ឋព្វ សម្ផស្ស, ៦ ធម្ម ធម្មារម្មណ៍ ។

**វិញ្ញាណ ៦ យ៉ាង**

១-ចក្ខុវិញ្ញាណ សេចក្ដីដឹងកើតតាមផ្លូវភ្នែក ។

២-សោតវិញ្ញាណ សេចក្តីដឹងកើតតាមផ្លូវត្រចៀក ។

៣-ឃានវិញ្ញាណ សេចក្តីដឹងកើតតាមផ្លូវច្រមុះ ។

៤-ជិវ្ហាវិញ្ញាណ សេចក្តីដឹងកើតតាមផ្លូវអណ្តាត ។

៥-កាយវិញ្ញាណ សេចក្តីដឹងកើតតាមផ្លូវកាយ ។

៦-មនោវិញ្ញាណ សេចក្តីដឹងកើតតាមផ្លូវចិត្ត ។

### សម្ផស្ស ៦

១- ចក្ខុសម្ផស្ស, ២- សោតសម្ផស្ស, ៣- ឃានសម្ផស្ស,

៤- ជិវ្ហាសម្ផស្ស, ៥- កាយសម្ផស្ស, ៦- វេទនាសម្ផស្ស ។

### វេទនា ៦

១- ចក្ខុសម្ផស្សជា វេទនា ២- សោតសម្ផស្សជា វេទនា

៣- ឃានសម្ផស្សជា វេទនា ៤- ជិវ្ហាសម្ផស្សជា វេទនា

៥- កាយសម្ផស្សជា វេទនា ៦- មនោសម្ផស្សជា វេទនា ។

### អភិញ្ញា ៦

១-ឥទ្ធិវិធិ សំដែងឫទ្ធីផ្សេងៗបាន ។

២-ទិព្វសោត ត្រចៀកដូចជាទិព្វ ។

៣-ចេតោបរិញ្ញាណ កំណត់ដឹងចិត្តរបស់អ្នកដទៃ ។

៤-បុព្វេនិវាសានុស្សតិ រឭកជាតិក្នុងកាលមុនៗបាន ។

៥-ចុតូបបាតញ្ញាណ ដឹងចុតិបដិសន្ធិនៃសត្វដោយទិព្វចក្ខុ ។

៦-អាសវក្ខយញ្ញាណ ដឹងធម៌ជាទីអស់នៃអាសវៈ ។

## សត្តកៈ ពួកធម៌ប្រាំពីរ

### រតនៈ កែវរបស់ស្តេចចក្រពត្តិ ៧ យ៉ាង

១-ចក្ករតនៈ ចក្រកែវ ។

២-ហត្ថិរតនៈ ដំរីកែវ ។

៣-អស្សរតនៈ សេះកែវ ។

៤-មណិរតនៈ កែវមណី ។

៥-ឥត្ថិរតនៈ ស្ត្រីកែវ ។

៦-គហបតិរតនៈ គហបតីកែវ ។

៧-បរិនាយករតនៈ មេទ័ពកែវឬព្រះរាជបុត្រច្បងដែលមានប្រាជ្ញា

### ធម៌ធ្វើឱ្យកើតជាព្រះឥន្ទ ៧ យ៉ាង

១-មាតាបេតិភរ ចិញ្ចឹមមាតាបិតា ។

២-កុលេជេដ្ឋាបចាយី គោរពកោតក្រែងចំពោះអ្នកដែលចំរើ ឬ ដែលជារៀមច្បងក្នុងត្រកូល ។

៣-សណ្ហវាច ពោលពាក្យពិរោះ ។

៤-បេសុណេយ្យប្បហាយី លះចោលនូវពាក្យញុះញង់ ។

៥-មច្ឆេរវិនយ នាំចេញនូវសេចក្តីកំណាញ់ពិសន្តាន ។

៦-សច្ច ពោលពាក្យពិត ។

៧-អក្កោធនិគ្គ គ្របសង្កត់នូវសេចក្តីក្រោធមិនឱ្យកើតបាន ។

### មិត្តប្រកបដោយអង្គ ៧ ប្រការគួរសេពគប់

១-ទុទ្ទនំ ទទាតិ ឱ្យរបស់ដែលគេឱ្យបានដោយកម្រ ។
២-ទុក្ករំ ករោតិ ធ្វើអំពើដែលគេធ្វើបានដោយកម្រ ។
៣-ទុក្ខមំ ខមតិ អត់ធន់នឹងការងារឬហេតុដែលគេអត់ធន់បាន ដោយកម្រ ។
៤-គុយ្ហមស្សអាចិក្ខតិ ប្រាប់សេចក្ដីកំបាំងដល់មិត្រ ។
៥-គុយ្ហមស្ស បរិគូហតិ លាក់សេចក្ដីកំបាំងរបស់មិត្រ ។
៦-អាបទាសុ ន ជហាតិ មិនលះបង់ចោលគ្នាក្នុងគ្រាដែលមាន សេចក្ដីអន្តរាយ ឬ មានវិបត្ត ។
៧-ខីណេ នាតិមញ្ញតិ កាលមិត្រអស់ទ្រព្យសម្បត្តិហើយ គឺ មិន មើលងាយ ។

**កិច្ចមិនគួរចូលទៅរកត្រកូលដែលប្រកបដោយអង្គ ៧ ប្រការ**

១-នមនាបេន បច្ចុដ្ឋេន្តិ គេមិនក្រោកទទួលដោយសេចក្ដីគាប់ចិត្ត។
២-នមនាបេន អភិវាទេន្តិ គេមិនថ្វាយបង្គំដោយសេចក្ដីគាប់ចិត្ត
៣-ន មនាបេន អាសនំ ទេន្តិ គេមិនអោយទីអង្គុយដោយសេចក្ដីគាប់ចិត្ត ។
៤-សន្តមស្ស បរិគូហន្តិ គេលាក់របស់ដែលមាន ។
៥-ពហុកម្ហិ ថោកំ ទេន្តិ គេមានវត្ថុច្រើន តែគេឱ្យបន្តិចបន្តួច
៦-បណីតម្ហិ លូខំ ទេន្តិ គេមានវត្ថុល្អ តែគេឱ្យវត្ថុអាក្រក់ ។
៧-អសក្កច្ចំ ទេន្តិ គេឱ្យដោយឥតមានគោរព ។

**កិច្ចគយរចូលទៅរកត្រកូលដែលប្រកបដោយអង្គ ៧ ប្រការ**

១-មនាបេន បច្ចុដ្ឋេន្តិ គេក្រោកទទួលដោយសេចក្ដីគាប់ចិត្ត ។
២-មនាបេន អភិវាទេន្តិ គេថ្វាយបង្គំដោយសេចក្ដីគាប់ចិត្ត ។
៣-មនាបេន អាសនំទេន្តិ គេឱ្យទីអង្គុយដោយសេចក្ដីគាប់ចិត្ត។
៤-សន្តមស្ស ន បរិគូហន្តិ គេមិនលាក់របស់ដែលមាន ។
៥-ពហុកម្ហិ ពហុកំ ទេន្តិ គេមានវត្ថុច្រើនគេឱ្យច្រើន ។
៦-បណីតម្ហិ បណីតំទេន្តិ គេមានវត្ថុល្អ គេឱ្យវត្ថុល្អ ។
៧-សក្កច្ចំ ទេន្តិ គេអោយដោយគោរព ។

**គ្រូអាចារ្យមានគុណសម្បត្តិ ៧ យ៉ាង**

១-បិយោ ជាទីស្រឡាញ់គាប់ចិត្ត ។
២-
៣-ភាវនីយោ ជាទីសរសើរ ។
៤-វត្តា ឧស្សាហ៍និយាយប្រដៅ ។
៥-វចនក្ខមោ អត់ធន់នឹងពាក្យសំដី ។
៦-គម្ភីរំ កថំ កត្តា ពោលពាក្យដ៏ជ្រាលជ្រៅ ។
៧-នោ អដ្ឋានេ និយោជេតិ មិនដឹកនាំសិស្សឱ្យឋិតនៅក្នុងផ្លូវឥត ប្រយោជន៍ ។

(អ្នករៀនកម្មដ្ឋានគួររកគ្រូអាចារ្យមានគុណសម្បត្តិដូច្នេះ)

**ភ្លើង ៧ យ៉ាង**

**១-រាគគ្គិ** ភ្លើង គឺ រាគៈ ។

**២-ទោសគ្គិ** ភ្លើង គឺ ទោសៈ ។

**៣-មោហគ្គិ** ភ្លើង គឺ មោហៈ ។

**៤-អាហុនេយ្យគ្គិ** ភ្លើង គឺ មាតាបិតា ។

**៥-ទក្ខិណេយ្យគ្គិ** ភ្លើង គឺ ព្រះអរិយៈ ជាទក្ខិណេយ្យបុគ្គល ។

**៦-គហបតគ្គិ** ភ្លើង គឺ គហបតី បានដល់ជនជាម្ចាស់ផ្ទះ ។

**៧-កដ្ឋគ្គិ** ភ្លើងដែលកើតអំពីកំណាត់ឈើ (ភ្លើងប្រក្រតី) ។

**ភរិយា ៧ យ៉ាង**

**១-វធកា ភរិយា** ភរិយាប្រាកដស្មើរដោយអ្នកសម្លាប់ ។

**២-ចោរា ភរិយា** ភរិយាប្រាកដស្មើដោយចោរ ។

**៣-អយ្យា ភរិយា** ភរិយាប្រាកដស្មើដោយម្ចាស់ឬនាយ ។

**៤-មាតា ភរិយា** ភរិយាប្រាកដស្មើដោយមាតា ។

**៥-ភគិនី ភរិយា** ភរិយាប្រាកដស្មើដោយប្អូនស្រី ។

**៦-សខី ភរិយា** ភរិយាប្រាកដស្មើដោយសំឡាញ់ ។

**៧-ទាសី ភរិយា** ភរិយាប្រាកដស្មើដោយខ្ញុំស្រី ។

**កម្មឱ្យផលផ្សេងគ្នា ៧ យ៉ាង**

១-មានអាយុវែង ព្រោះមិនសម្លាប់សត្វ ។

២-មិនមានរោគ ព្រោះមិនបៀតបៀនសត្វ ។

៣-មានសម្បុរល្អ ព្រោះមិនក្រេវក្រោធពិរោធ ។

៤-មានតេជានុភាពច្រើន ព្រោះមិនច្រណែនឈ្នានីសគេ ។

៥-មានទ្រព្យសម្បត្តិច្រើន ព្រោះបរិច្ចាគទាន ។

៦-មានត្រកូលខ្ពង់ខ្ពស់ ព្រោះគោរពកោតក្រែងចំពោះចាស់ព្រឹទ្ធាចារ្យ ។

៧-មានប្រាជ្ញា ព្រោះសេពគប់នឹងសប្បុរស់ ។

**សប្បុរិសធម៌ ៧ យ៉ាង**

**១-ធម្មញ្ញុតា** ភាពជាអ្នកដឹងធម៌ គឺ ដឹងហេតុ ។

**២-អត្ថញ្ញុតា** ភាពជាអ្នកដឹងអត្ថ គឺ ដឹងផល ។

**៣-អត្តញ្ញុតា** ភាពជាអ្នកដឹង ។

**៤-មត្តញ្ញុតា** ភាពជាអ្នកដឹងប្រមាណ ។

**៥-កាលញ្ញុតា** ភាពជាអ្នកដឹងកាល ។

**៦-បរិសញ្ញុតា** ភាពជាអ្នកដឹងបរិស័ទ ។

**៧-បុគ្គលបរោបរញ្ញុតា** ភាពជាអ្នកដឹងបុគ្គលខ្ពស់ទាប ។

**សទ្ធម្ម ៧ យ៉ាង**

**១-សទ្ធា** ការជឿកម្មនឹងផលកម្ម ឬ ជឿហេតុដែលគួរជឿ ។

**២-ហិរិ** សេចក្តីខ្មាស់បាប ខ្មាស់ទុច្ចរិត ។

**៣-ឱត្តប្ប** សេចក្តីស្លុតខ្លាចបាប ទុច្ចរិត ។

**៤-ពាហុសច្ចំ** ភាពជាអ្នកបានរៀន បានស្តាប់ច្រើន ។

**៥-វីរិយំ** ព្យាយាម ។

**៦-សតិ** សេចក្តីរលឹក ។

**៧-បញ្ញា** សេចក្តីដឹងសព្វ ។

## អរិយទ្រព្យ ៧ យ៉ាង

**១-សទ្ធា** សេចក្តីជឿចំពោះហេតុដែលគួរជឿ ។

**២-សីល** រក្សាសីល ។

**៣-ហិរិ** សេចក្តីខ្មាស់បាប ខ្មាស់ទុច្ចរិត្ត ។

**៤-ឱត្តប្ប** សេចក្តីស្លុតខ្លាចបាប ទុច្ចរិត ។

**៥-ពាហុសច្ចំ** ភាពជាអ្នកបានរៀន បានស្តាប់ ។

**៦-ចាគ** លះទ្រព្យរបស់ខ្លួនឱ្យដល់បុគ្គលដែលគួរឱ្យ ។

**៧-បញ្ញា** ប្រាជ្ញា ។

## ជាតិទុក្ខ ៧ យ៉ាង

**១-គព្ភោក្កន្តិមូលកទុក្ខ** ទុក្ខមានការចុះកាន់គភ៌ជាមូល ។

**២-គព្ភបរិហរណមូលកទុក្ខ** ទុក្ខមានការថែរក្សាគភ៌ជាមូល ។

**៣-គព្ភវិបត្តិមូលកទុក្ខ** ទុក្ខមានវិបត្តិនៃគភ៌ជាមូល ។

**៤-គព្ភវិជាយនមូលកទុក្ខ** ទុក្ខមានការកំពង់សម្រាលចាគគភ៌ជាមូល ។

**៥-គព្ភនិក្ខមនមូលកទុក្ខ** ទុក្ខមានការចេញចាកគភ៌ជាមូល ។

**៦-អត្តូបក្កមមូលកទុក្ខ** ទុក្ខមានសេចក្តីព្យាយាមរបស់ខ្លួនជាមូល

**៧-បរូបក្កមមូលកទុក្ខ** ទុក្ខមានព្យាយាមរបស់អ្នកដ៏ទៃជាមូល ។

## ជរាទុក្ខ ៧ យ៉ាង

**១-ទុព្វណ្ណោ** មានសម្បុរអាក្រក់ ។

**២-ទុព្វលោ** មានកំឡាំងថមថយ ។

**៣- កាយោ** មានរាងកាយចាស់ត្រុតទ្រោម ។

**៤-ភច្ចិតសរីរោ** មានសរីរអាវៈយវៈញញាក់ញញូរ ។

**៥-ឆិន្នទន្តោ** មានធ្មេញបាក់

**៦-ជរចក្ខុ** មានភ្នែកជរា គឺ ស្រវាំងឬងងឹត ។

**៧-ជរសោតោ** មានត្រចៀកជរា គឺស្តាប់មិនច្បាស់ឬថ្លង់ ។

## ភិក្ខុប្រកបដោយធម៌ ៧ យ៉ាង ឈ្មោះថាធ្វើអាសវៈឱ្យអស់បាន

**១-សទ្ធោ ហោតិ** ជាអ្នកមានសទ្ធា ។

**២-សីលវា ហោតិ** ជាអ្នកមានសីល ។

**៣-ពហុស្សុតោ ហោតិ** ជាពហុស្សូត ។

**៤-បដិសល្លីនោ ហោតិ** ជាអ្នកថយចេញចាកពួកទៅរកទីស្ងាត់ ។

**៥-អារទ្ធវីរិយោ ហោតិ** ជាអ្នកមានព្យាយាម ។

**៦-សតិមា ហោតិ** ជាអ្នកមានសតិ ។

**៧-បញ្ញវា ហោតិ** ជាអ្នកមានប្រាជ្ញា ។

### សមាធិបរិក្ខារ "ធម៌ជាបរិក្ខារនៃសមាធិ" ៧ យ៉ាង

១-**សម្មាទិដ្ឋិ** ការយល់ឃើញត្រូវ ។

២-**សម្មាសង្កប្បៈ** ការត្រិះរិះត្រូវ ។

៣-**សម្មាវាចា** ការនិយាយត្រូវ ។

៤-**សម្មាកម្មន្តៈ** ការងារត្រូវ ។

៥-**សម្មាអាជីវៈ** ការចិញ្ចឹមជីវិតត្រូវ ។

៦-**សម្មាវាយាមៈ** ព្យាយាមត្រូវ ។

៧-**សម្មាសតិ** សេចក្តីរលឹកត្រូវ ។

### អនុសយ "កិលេសដេកនៅរឿយៗក្នុងចិត្ត" ៧ យ៉ាង

១-កាមរាគានុស័យ, ២-បដិឃានុស័យ, ៣-មានានុស័យ,

៤-ទិដ្ឋានុស័យ, ៥-វិចិកិច្ឆានុស័យ, ៦- នុស័យ

៧-អវិជ្ជានុស័យ, ។

### សល្ល "ធម៌ប្រៀបដូចជាព្រួញ" ៧ យ៉ាង

១-**រាគសល្ល** ព្រួញ គឺ រាគៈ ។

២-**ទោសសល្ល** ព្រួញ គឺ ទោសៈ ។

៣-**មោហសល្ល** ព្រួញ គឺ មោហៈ ។

៤-**មានសល្ល** ព្រួញ គឺ មានៈ ។

៥-**សោកសល្ល** ព្រួញ គឺ សោកៈ ។

៦-**កថំកថាសល្ល** ព្រួញ គឺ សេចក្តីសង្ស័យ ។

៧-**ទិដ្ឋិសល្ល** ព្រួញ គឺសេចក្តីយល់ឃើញខុស ។

### មហាឋាន "កន្លែងដ៏ប្រសើរ" ៧ យ៉ាង

១-ពោធិបល្លង្ក, ២-អនិមិ្មសចេតិយ, ៣-រតនចង្កម,

៤-រតនឃរ, ៥-អជបាលនិគ្រោធ, ៦-ស្រះមុច្ចលិន្ទ,

៧-រាជាយតនចេតិយ, ។

### សហជាត "ដែលកើតដំណាលគ្នានឹងថ្ងៃដែលព្រះពុទ្ធទ្រង់ប្រសូត្រ" ៧ យ៉ាង

១-រាហុលមាតាទេវី, ២-ឆន្នមាត្យ, ៣-កាឡុទាយិអាមាត្យ,

៤-ព្រះអានន្ទ, ៥-សេះកណ្ឋក, ៦-ដើមមហាពោធិព្រឹក្ស,

៧-កំណប់ទ្រព្យទាំង ៤ ។

### ធម៌ជាបច្ច័យនឹងគ្នា ៧ យ៉ាង

១-**ហិរិឱត្តប្បៈ** ជាបច្ច័យនៃឥន្រ្ទិយសំវរៈ ។

២-**ឥន្ទ្រិយសំវរៈ** ជាបច្ច័យនៃសីល ។

៣-**សីល** ជាបច្ច័យនៃសម្មាសមាធិ ។

៤-**សម្មាសមាធិ** ជាបច្ច័យនៃយថាភូតញ្ញាណទស្សនៈ ។

៥-**យថាភូតញ្ញាណទស្សនៈ** ជាបច្ច័យនៃនិព្វិទាវិរាគៈ ។

៦-**និព្វិទាវិរាគ** ជាបច្ច័យនៃវិមុត្តិ ។

៧-**វិមុត្តិ** ជាធម៌ទីបំផុត ។

### ធម៌គួរចំរើន ៧ យ៉ាង

១-អនិច្ចសញ្ញា សេចក្ដីសំគាល់ថាមិនទៀង ។
២-អនត្តសញ្ញា សេចក្ដីសំគាល់ថាមិនមែនខ្លួនប្រាណ ។
៣-អសុភសញ្ញា សេចក្ដីសំគាល់ថាមិនល្អ ។
៤-អាទីនវសញ្ញា សេចក្ដីសំគាល់ថាមិនមែនជាទោស ។
៥-បហានសញ្ញា សេចក្ដីសំគាល់ក្នុងការចេះ ។
៦-វិរាគសញ្ញា សេចក្ដីសំគាល់ក្នុងធម៌ប្រាសចាករាគៈ ។
៧-និរោធសញ្ញា សេចក្ដីសំគាល់ក្នុងធម៌ជាទីរលត់ ។

### គ្រឿងវិនិច្ឆ័យថាមិនមែនជាធម៌វិន័យ ៧ យ៉ាង

១-ធម៌ដែលមិនប្រព្រឹត្តទៅ ដើម្បី និព្វិទា ។
២-ធម៌ដែលមិនប្រព្រឹត្តទៅ ដើម្បី វិរាគៈ ។
៣-ធម៌ដែលមិនប្រព្រឹត្តទៅ ដើម្បី និរោធៈ ។
៤-ធម៌ដែលមិនប្រព្រឹត្តទៅ ដើម្បី ឧបសមៈ ។
៥-ធម៌ដែលមិនប្រព្រឹត្តទៅ ដើម្បី អភិញ្ញា ។
៦-ធម៌ដែលមិនប្រព្រឹត្តទៅ ដើម្បី សម្ពោធៈ ។
៧-ធម៌ដែលមិនប្រព្រឹត្តទៅ ដើម្បី និព្វាន ។

(ធម៌នេះ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ចំពោះព្រះឧបាលិត្ថេរ)

### គ្រឿងវិនិច្ឆ័យជាធម៌វិន័យ ៧ យ៉ាង

១-ធម៌ដែលប្រព្រឹត្តទៅ ដើម្បី និព្វិទា ។
២-ធម៌ដែលប្រព្រឹត្តទៅ ដើម្បី វិរាគៈ ។
៣-ធម៌ដែលប្រព្រឹត្តទៅ ដើម្បី និរោធៈ ។
៤-ធម៌ដែលប្រព្រឹត្តទៅ ដើម្បី ឧបសមៈ ។
៥-ធម៌ដែលប្រព្រឹត្តទៅ ដើម្បី អភិញ្ញា ។
៦-ធម៌ដែលប្រព្រឹត្តទៅ ដើម្បី សម្ពោធៈ ។
៧-ធម៌ដែលប្រព្រឹត្តទៅ ដើម្បី និព្វាន ។

(មើលមិនរួច ទំព័រ១១៤)

### ពោជ្ឈង្គ ៧ យ៉ាង

១-សតិ សេចក្ដីរលឹក ។
២-
៣-វីរិយ ព្យាយាម ។
៤-បីតិ សេចក្ដីឆ្អែតចិត្ត ។
៥-បស្សទ្ធិ សេចក្ដីស្ងប់កាយ ស្ងប់ចិត្ត ។
៦-សមាធិ សេចក្ដីតាំងចិត្ត ។
៧-ឧបេក្ខា សេចក្ដីព្រងើយកន្តើយ ។

### ធម៌ដែលប្រព្រឹត្តទៅដើម្បីមិនសាបសូន្យ ៧ យ៉ាង

១-សត្ថុគារវតា គោរពចំពោះព្រះសាស្ដា ។
២-ធម្មគារវតា គោរពចំពោះព្រះធម៌ ។
៣-សង្ឃគារវតា គោរពចំពោះព្រះសង្ឃ ។
៤-សិក្ខាគារវតា គោរពចំពោះសិក្ខា ។

**៥-សមាធិគារវតា** គោរពចំពោះសមាធិ ។

**៦-សោវចស្សតា** ធ្វើខ្លួនឱ្យ ។

**៧-កល្យាណមិត្តតា** មានកល្យាណមិត្រ ។

## សង្ឃគតាទក្ខិណាទាន ៧ យ៉ាង

១-ឱ្យទានដល់ឧភតោសង្ឃ មានព្រះពុទ្ធជាប្រធាន ។

២-ឱ្យទានដល់ឧភតោសង្ឃ ឥតមានព្រះពុទ្ធជាប្រធាន ។

៣-ឱ្យទានដល់ភិក្ខុសង្ឃ ។

៤-ឱ្យទានដល់ភិក្ខុនីសង្ឃ ។

៥-ឱ្យទានដល់ភិក្ខុដែលនិមន្តចំពោះអំពីសំណាក់ឧភតោសង្ឃ ។

៦-ឱ្យទានដល់ភិក្ខុដែលនិមន្តចំពោះអំពីសំណាក់ភិក្ខុសង្ឃ ។

៧-ឱ្យទានដល់ភិក្ខុនីដែលនិមន្តចំពោះអំពីសំណាក់ភិក្ខុនីសង្ឃ ។

## ភិក្ខុប្រកបដោយធម៌ ៧ យ៉ាងជាទីស្រឡាញ់នៃសព្រហ្មចារី

**១-ន លាភកាមោ** មិនប្រាថ្នាលាភ ។

**២-ន សក្ការកាមោ** មិនប្រាថ្នាសក្ការៈ ។

**៣-ន អនញ្ញត្តិកាមោ** មិនប្រកាន់ខ្លួន ។

**៤-ហិរិមា** មានហិរិ ។

**៥-ឱត្តប្បី** មានឱត្តប្បៈ ។

**៦-អនុស្សុកី** មិនមានសេចក្តីរចណែនឈ្នានីស ។

**៧-អមច្ឆរី** មិនមានសេចក្តីកំណាញ់ ។

## វិបត្តិរបស់ឧបាសក ៧ យ៉ាង

**១-ភិក្ខុទស្សនំ ហាបេតិ** បោះបង់លែងទៅជួបប្រទះនឹងភិក្ខុសង្ឃ ។

**២-សទ្ធម្មស្សវនំ មជ្ជតិ** ប្រមាទក្នុងការស្តាប់ព្រះសទ្ធម្ម ។

**៣-អធិសីលេ ន សិក្ខតិ** មិនសិក្សាក្នុងអធិសីល គឺ សីល ៥ និង សីល ១០ ។

**៤-អប្បសាទពហុលោ ហោតិ** ច្រើនដោយសេចក្តីមិនជ្រះថ្លា ។

**៥-ឧចារម្ភចិត្តោ ធម្មំ សុណាតិ រន្ធគវេសី** កំពុងស្តាប់ធម៌មានចិត្តក្រេវក្រោធ ឬ តិះដៀលស្វែងរកទោស ។

**៦-ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ** ស្វែងរកបុគ្គលអ្នកទទួលទេយ្យធម៌ខាងក្រៅព្រះពុទ្ធសាសនា ។

**៧-តត្ថ ច បុព្វការំ ករោតិ** ធ្វើតានចំពោះតិរ្ថិយខាងក្រៅព្រះពុទ្ធសាសនា ។

## សម្បទារបស់ឧបាសក ៧ យ៉ាង

**១-ភិក្ខុទស្សនំ ន ហាបេតិ** ឧស្សាហ៍ជួបប្រទះនឹងភិក្ខុសង្ឃ ។

**២-សទ្ធម្មស្សវនំ នប្បមជ្ជតិ** មិនប្រមាទក្នុងការស្តាប់ព្រះសទ្ធម្ម ។

**៣-អធិសីលេ សិក្ខតិ** សិក្សាក្នុងអធិសីល ។

**៤-បសាទពហុលោ ហោតិ** មានសេចក្តីជ្រះថ្លាច្រើន ។

**៥-អនុបារម្ភចិត្តោ ធម្មំ សុណាតិ ន រន្ធគវេសី** កំពុងស្តាប់ធម៌មានចិត្តមិនក្រេវក្រោធ ឬ មិនតិះដៀលមិនស្វែងរកទោស ។

**៦-ន ឥតោ ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ** មិនស្វែងរកទក្ខិណេយ្យ បុគ្គលខាងក្រៅព្រះពុទ្ធសាសនា ។

**៧-ឥធ ច បុព្វការំ ករោតិ** ធ្វើទានចំពោះតែទក្ខិណេយ្យបុគ្គលក្នុងព្រះពុទ្ធសាសនា ។

**ឧទកូបមបុគ្គល**"បុគ្គលប្រៀបដូចអ្នកមុជទឹក" **៧ យ៉ាង**

**១-សកឹ និមុគ្គោ និមុគ្គោវ ហោតិ** មុជចុះម្ដងក៏ចេះតែមុជចុះរហូត(បានដល់និយតមិច្ឆាទិដ្ឋិកបុគ្គល) ។

**២-ឧម្មុជ្ជិត្វា និមុជ្ជតិ** ងើបឡើងហើយមុជចុះទៅវិញ(បានដល់បុគ្គលដែលមានសីលជាដើមហើយបោះបង់ចោលទៅវិញ) ។

**៣-ឧម្មុជ្ជិត្វា ឋិតោ ហោតិ** ងើបឡើងហើយឈរទ្រឹង(បានដល់កល្យាណបុថុជ្ជន) ។

**៤-ឧម្មុជ្ជិត្វា វិបស្សតិ វិលោកេតិ** ងើបឡើយហើយសំឡឹងរកមើលទិសដែលត្រូវទៅ(បានដល់សោតាបន្នបុគ្គល) ។

**៥-ឧម្មុជ្ជិត្វា បតរតិ** ងើបឡើងហើយបែរមុខទៅរកទិសដែលត្រូវទៅ(បានដល់សកទាគាមិបុគ្គល) ។

**៦-ឧម្មុជ្ជិត្វា បតិគាធប្បត្តោ ហោតិ** ងើបឡើងហើយឆ្លងទៅសល់មាត់ច្រាំង ក៏ឈប់នៅទីនោះមិនត្រឡប់មកវិញ(បានដល់អនាគាមិបុគ្គល) ។

**៧-ឧម្មុជ្ជិត្វា តិណ្ណោ ហោតិ** ងើបឡើងហើយហែលឆ្លងទៅដល់ត្រើយនាយឡើងទៅឈរលើគោក(បានដល់ព្រះអរហន្ត)

**អបរិហានិយធម៌**"ធម៌ប្រព្រឹត្តទៅដើម្បីសេចក្ដីចំរើន" **៧ យ៉ាង**

**១**-ឧស្សាហ៍ប្រជុំគ្នារឿយៗ ។

**២**-កាលប្រជុំគ្នា ក៏ព្រមព្រៀងគ្នាប្រជុំ កាលក្រោកចាកទីប្រជុំក៏ប្រមព្រៀងគ្នាក្រោក នឹងព្រមព្រៀងគ្នាជួយធ្វើកិច្ចការដែលសង្ឃត្រូវធ្វើ ។

**៣**-មិនបញ្ញត្តបន្ថែមនូវសិក្ខាបទដែលព្រះអង្គមិនបានបញ្ញត្ត, មិនដកហូតសិក្ខាបទ ដែលព្រះអង្គបញ្ញត្តរួចហើយ, ប្រព្រឹត្តកាន់តាមតែសិក្ខាបទ ដែលព្រះអង្គទ្រង់បញ្ញត្តហើយ ។

**៤**-ធ្វើសក្ការៈគោរពរាប់អានបូជាចំពោះលោកជាថេរៈ ជាសង្ឃនិតាធានាយកលើសង្ឃ ព្រមទាំងជឿស្ដាប់ឱវាទរបស់លោក ។

**៥**-មិនលោះក្នុងអំណាចនៃតណ្ហាដែលកើតឡើង ។

**៦**-ចូលចិត្តអាស្រ័យនៅក្នុងទីសេនាសនៈដែលមាននៅក្នុងព្រៃ ។

**៧**-តាំងចិត្តថា សព្រហ្មចារីបុគ្គលទាំងឡាយ ដែលមានសីលជាទីស្រឡាញ់ ដែលមិនទាន់បាននិមន្តមកកាន់អាវាសនេះ ក៏សូមឱ្យលោក(មើលមិនរួចចុងទំព័រទី ១១៩)

**អដ្ឋកៈ ពួកធម៌ប្រាំបី**

**ធម្មសមោធាន ៨ ប្រការ**

**១-មនុស្សត្តំ** ជាតិមនុស្ស ។

**២-លិង្គសម្បត្តិ** ដល់ព្រមដោយភេទជាបុរស ។

**៣-ហេតុ** មានឧបនិស្ស័យគួរនឹងសម្រេចអរហត្តផល ។

**៤-សត្ថារទស្សនំ** បានជួបនឹងព្រះបរមសាស្តា ។

**៥-បព្វជ្ជា** បានបួសក្នុងព្រះពុទ្ធសាសនា ឬ បួសជាតាបសក្រៅព្រះពុទ្ធសាសនា ។

**៦-គុណសម្បត្តិ** ដល់ប្រមដោយគុណសម្បត្តិមានឈានជាដើម។

**៧-អធិការោ** បានធ្វើតានដ៏ឧត្តម មានមហាបរិច្ចាគ៥ជាដើម ។

**៨-ឆន្ទតា** ពេញចិត្តប្រាថ្នានូវពោធិញ្ញាណ ។

(ធម៌ ៨ប្រការនេះអាចញ៉ាំងសេចក្តីប្រាថ្នាពោធិញ្ញាណឱ្យសម្រេចបាន) ។

### បុគ្គលជាបុញ្ញក្ខេត្តដ៏ប្រសើរមាន ៨ ពួក

**១-សោតាបន្នោ** លោកជាសោតាបន្នបុគ្គល ។

**២-សោតាបត្តិផល សច្ឆិកិរិយាយ បដិបន្នោ** លោកដែលប្រតិ-បត្តដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល ។

**៣-សកទាគាមិ** លោកជាសកទាគាមិបុគ្គល ។

**៤-សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ** លោកដែលប្រតិ-បត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសកទាគាមិផល ។

**៥-អនាគាមិ** លោកជាអនាគាមិបុគ្គល ។

**៦-អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ** លោកដែលប្រតិបត្តិដើម្បិធ្វើឱ្យជាក់ច្បាស់នូវអនាគាមិផល ។

**៧-អរហា** លោកជាព្រះអរហន្ត ។

**៨-អរហត្តាយ បដិបន្នោ** លោកដែលប្រតិបត្តិដើម្បីអរហត្តផល ។

### សប្បុរិសទាន ៨

**១-សុចឹ ទេតិ** អោយវត្ថុដ៏ស្អាត ។

**២-បណីតំ ទេតិ** អោយវត្ថុដ៏ឧត្តមថ្លៃថ្លា ។

**៣-កាលេន ទេតិ** អោយទានតាមកាលសម័យ ។

**៤-កប្បិយំ ទេតិ** អោយវត្ថុជារបស់គយរ ។

**៥-វិចេយ្យ ទេតិ** ពិចារណាហើយទើបអោយ ។

**៦-អភិណ្ហំ ទេតិ** អោយទានរឿយ ៗ ។

**៧-ទទំ ចិត្តំ បសាទេតិ** កំពុងអោយទានធ្វើចិត្តជ្រះថ្លា ។

**៨-ទត្វា អត្តមនោ ហោតិ** លុះឱ្យទានរួចហើយមានចិត្តត្រេកអរ ។

### បដិគ្គាហកដែលធ្វើតានទាយកឱ្យថយផល ៨ ពួក

**១-មិច្ឆាទិដ្ឋិកា** មានសេចក្តីឃើញខុស ។

**២-មិច្ឆាសង្កប្បា** មានការត្រិះរិះខុស ។

**៣-មិច្ឆាវាចា** មានវាចាខុស ។

**៤-មិច្ឆាកម្មន្តា** មានការងារខុស ។

**៥-មិច្ឆាអាជីវា** មានការចិញ្ចឹមជីវិតខុស ។

**៦-មិច្ឆាវាយាមា** មានព្យាយាមខុស ។

**៧-មិច្ឆាសតិនោ** មានសតិខុស ។

**៨-មិច្ឆាសមាធិនោ** មានការតាំងចិត្តខុស ។

### បដិគ្គាហកដែលធ្វើទាននាំឱ្យមានផលច្រើន ៨ ពួក

**១-សម្មាទិដ្ឋិកា** មានសេចក្តីឃើញត្រូវ ។

**២-សម្មាសង្កប្បា** មានការត្រិះរិះត្រូវ ។

**៣-សម្មាវាចា** មានវាចាត្រូវ ។

**៤-សម្មាកម្មន្តា** មានការងារត្រូវ ។

**៥-សម្មាអាជីវា** មានការចិញ្ចឹមជីវិតត្រូវ ។

**៦-សម្មាវាយាមា** មានព្យាយាមត្រូវ ។

**៧-សម្មាសតិនោ** មានសតិត្រូវ ។

**៨-សម្មាសមាធិនោ** មានការតាំងចិត្តត្រូវ ។

### ទានវត្ថុ "ហេតុដែលនាំឱ្យធ្វើទាន" ៨ យ៉ាង

**១-ឆន្ទទានំ** ឱ្យទានដោយសេចក្តីស្រឡាញ់ ។

**២-ទោសទានំ** ឱ្យទានដោយសេចក្តីក្រោធ ។

**៣-មោហទានំ** ឱ្យទានដោយសេចក្តីវង្វេង ។

**៤-ភយទានំ** ឱ្យទានដោយសេចក្តីខ្លាច ។

**៥-ទិន្នបុព្វទានំ** ឱ្យទានដោយគិតថាត្រកូលរបស់ខ្លួនធ្លាប់តែឱ្យទានមក ។

**៦-សុគតិឧប្បជ្ជនទានំ** ឱ្យទានដោយតាំងចិត្តថានឹងបានទៅកើតក្នុងសុគតិ ។

**៧-ចិត្តប្បសាទនទានំ** ឱ្យទានដោយគិតថាកាលអាត្មាអញកំពុងឱ្យទាននឹងកើតចិត្តជ្រះថ្លា ។

**៨-ចិត្តាលង្ការទានំ** ឱ្យទានដើម្បីជាគ្រឿងប្រដាប់ឬជាគ្រឿងបរិក្ខារនៃចិត្ត(ចំពោះសមថវិបស្សនាចិត្ត) ។

### ទានូបបត្តិ "កន្លែងដែលអ្នកធ្វើទានចង់ទៅកើត" ៨ យ៉ាង

**១-មហាសាលទានំ** ឱ្យទានព្រោះចង់ទៅកើតក្នុងត្រកូលមហាសាល

**២-ចាតុម្មហារាជិកទានំ** ឱ្យទានព្រោះចង់កើតក្នុងឋានចាតុម្មហារា-ជិកា ។

**៣-តាវត្តឹសទានំ** ឱ្យទានព្រោះចង់កើតក្នុងឋានតាវត្តឹង្ស ។

**៤-យាមាទានំ** ឱ្យទានព្រោះចង់ទៅកើតក្នុងឋានយាមា ។

**៥-តុសិតទានំ** ឱ្យទានព្រោះចង់ទៅកើតក្នុងឋានតុសិត ។

**៦-និម្មានរតិទានំ** ឱ្យទានព្រោះចង់ទៅកើតក្នុងឋាននិម្មានរតី ។

**៧-បរនិម្មិតវសវត្តិទានំ** ឱ្យទានព្រោះចង់ទៅកើតក្នុងឋានបរនិម្មិ-តវសវត្តិ ។

**៨-ព្រហ្មលោកទានំ** ឱ្យទានព្រោះចង់ទៅកើតព្រហ្មលោក ។

### មិច្ឆត្ត ភាវៈនៃសេចក្តីខុស ៨

**១-មិច្ឆាទិដ្ឋិ** ការឃើញខុស ។

**២-មិច្ឆាសង្កប្ប** ត្រិះរិះខុស ។

**៣-មិច្ឆាវាចា** វាចាខុស ។

**៤-មិច្ឆាកម្មន្ត** ការងារខុស ។

**៥-មិច្ឆាអាជីវ** ការចិញ្ចឹមជីវិតខុស ។

**៦-មិច្ឆាវាយាម** ព្យាយាមខុស ។

៧-មិច្ឆាសតិ សតិខុស ។

៨-មិច្ឆាសមាធិ សមាធិខុស ។

### មគ្គ ៨

១-សម្មាទិដ្ឋិ ប្រាជ្ញាឃើញត្រូវ ។

២-សម្មាសង្កប្ប ការត្រិះរិះត្រូវ ។

៣-សម្មាវាចា វាចាត្រូវ ។

៤-សម្មាកម្មន្ត ការងារត្រូវ ។

៥-សម្មាអាជីវ ការចិញ្ចឹមជីវិតត្រូវ ។

៦-សម្មាវាយាម ព្យាយាមត្រូវ ។

៧-សម្មាសតិ សេចក្តីរលឹកត្រូវ ។

៨-សម្មាសមាធិ ការតាំងចិត្តឱ្យនឹងត្រូវ ។

### សេចក្តីសុខរបស់សមណៈ ៨ យ៉ាង

១-មិនមានការហួងហែងរក្សាទុកនូវសម្បត្តិ មានស្រូវជាដើម ។

២-ស្វែងរកតែបិណ្ឌបាតដែលឥតទោស ។

៣-បរិភោគតែអាហារដែលឆ្អិនស្រាប់ ។

៤-មិនមានសេចក្តីលំបាកដោយការបៀតបៀនអំពីដែន

គឺមិនត្រូវ បង់ពន្ធដារជាដើម ។

៥-មិនមានឆន្ទរាគចំពោះគ្រឿងឧបករណ៍ ។

៦-មិនមានភ័យព្រោះចោរប្លន់ ។

៧-មិនជាប់ជំពាក់ដោយស្តេច នឹងអមាត្យស្តេច ។

៨-ឥតមានអ្នកណារារាំងឃាត់ឃាំងក្នុងទិសទាំង ៤ ។

### មនុស្សឆ្កួត ៨ ពួក

១-កាមុម្មត្តកោ ឆ្កួតព្រោះកាម ។

២-កោធុម្មត្តកោ ឆ្កួតព្រោះសេចក្តីក្រោធ ។

៣-ទិដ្ឋុម្មត្តកោ ឆ្កួតព្រោះសេចក្តីយល់ឃើញខុស ។

៤-មោហុម្មត្តកោ ឆ្កួតព្រោះសេចក្តីវង្វេង ។

៥-យក្ខុម្មត្តកោ ឆ្កួតព្រោះយក្សចូលបៀតបៀន ។

៦-បិត្តុម្មត្តកោ ឆ្កួតព្រោះកំរើកប្រមាត់ ។

៧-សុរុម្មត្តកោ ឆ្កួតព្រោះសុរា ។

៨-ព្យសនុម្មត្តកោ ឆ្កួតព្រោះចួបប្រទះនឹងសេចក្តីវិនាស ។

### អបាយមុខ ៨ យ៉ាង

១-ឥត្ថីសោណ្ឌ ជាអ្នកលេងស្រ្តី ។

២-សុរាសោណ្ឌ ជាអ្នកលេងសុរា ។

៣-អក្ខសោណ្ឌ ជាអ្នកលេងស៊ីនំ ។

៤-អត្ថធុត្ត ជាអ្នកលេងល្បែងភ្នាល់ ។

៥-បាបមិត្ត មានមិត្រអាក្រក់ ។

៦-អាលស្យ ភាពជាអ្នកខ្ជិលច្រអូស ។

៧-វត្តិយាវិចរណេ ដើរលេងក្នុងវេលាយប់ ។

៨-សមជ្ជាភិចរណេ ដើរមើលល្បែងមហោស្រព ។

### លោកធម៌ ៨ យ៉ាង

១-លាភោ មានលាភ, ២-អលាភោ មិនមានលាភ,
៣-យសោ មានយស, ៤-អយសោ មិនមានយស,
៥-និន្ទា ការតិះដៀល, ៦-បសំសា សេចក្តីសរសើរ,
៧-សុខំ សេចក្តីសុខ, ៨-ទុក្ខំ សេចក្តីតុក្ខ,

## មន្ទិល ៨ យ៉ាង

១-អសជ្ឈាយមលា មន្តា មន្ត ឬ ចំណេះវិជ្ជា មានការមិនស្វាធ្យាយន៍ជាមន្ទិល ។

២-អនុដ្ឋានមលា ឃរា ផ្ទះមានការមិនឧស្សាហ៍ថែទាំជាមន្ទិល។

៣-មលំ វណ្ណស្ស កោសជ្ជំ សេចក្តីខ្ជិល ជាមន្ទិលនៃសម្បុរ។

៤-បមាទោ រក្ខតោមលំ សេចក្តីប្រហែសធ្វេស ជាមន្ទិលនៃការរក្សា ។

៥-មលិត្ថិយា ទុច្ចរិតំ ការប្រព្រឹត្តអាក្រក់ ជាមន្ទិលរបស់ស្ត្រី ។

៦-មច្ឆេរំ ទទតោ មលំ សេចក្តីកំណាញ់ជាមន្ទិលនៃការឱ្យទាន។

៧-មលា វេ បាបកា ធម្មា អស្មឹ លោកេ បរម្ហិ ច បាបធម៌ទាំងឡាយជាមន្ទិលក្នុងលោកនេះនឹងបរលោក ។

៨-តតោ មលា មលតរំ អវិជ្ជា បរមំ មលំ អវិជ្ជាជាមន្ទិលដ៏ក្រៃលែងជាងមន្ទិលទាំងអស់ ។

## សំវេគវត្ថុ "ហេតុនាំឱ្យកើតសំវេគ" ៨ យ៉ាង

១-ជាតិទុក្ខ រំពឹងដល់ទុក្ខក្នុងការកើត ។
២-ជរាទុក្ខ រំពឹងដល់ទុក្ខក្នុងការចាស់គ្រាំគ្រា ។
៣-ព្យាធិទុក្ខ រំពឹងដល់ទុក្ខក្នុងការឈឺចាប់ ។
៤-មរណទុក្ខ រំពឹងដល់ទុក្ខក្នុងការស្លាប់ ។
៥-អបាយទុក្ខ រំពឹងដល់ទុក្ខក្នុងអបាយ ។
៦-អតីតទុក្ខ រំពឹងដល់ទុក្ខក្នុងអតីត ។
៧-អនាគតទុក្ខ រំពឹងដល់ទុក្ខក្នុងអនាគត ។
៨-អាហារបរិយេដ្ឋិតទុក្ខ រំពឹងដល់ទុក្ខក្នុងការស្វែងរកអាហារ ។

## មហានរក ៨ រណ្តៅ

១-សញ្ជិវៈ, ២-កាលសុតៈ, ៣-សង្ឃាដៈ, ៤-រោរវៈ,
៥-មហារោរវៈ, ៦-តាបៈ, ៧-មហាតាបៈ, ៨-អវិចិ, ។

## អក្ខណអសម័យ ៨ យ៉ាង

១-កើតក្នុងនរក ។
២-កើតក្នុងកំណើតតិរច្ឆាន ។
៣-កើតក្នុងប្រេតវិស័យ ។
៤-កើតជាព្រហ្មមានអាយុវែង ។
៥-កើតជាមនុស្សក្នុងបច្ចន្តប្រទេស ។
៦-កើតជាមនុស្សក្នុងមជ្ឈិមប្រទេស តែជាមនុស្សលីលា ។
៧-កើតជាមនុស្សក្នុងមជ្ឈិមប្រទេស តែជាមិច្ឆាទិដ្ឋិ ។
៨-កើតខាងក្រៅពុទ្ធកាល ។

## កិលេសវត្ថុ ៨ យ៉ាង

១-លោភៈ, ២-ទោសៈ, ៣-មោហៈ, ៤-មានៈ, ៥-ទិដ្ឋិ,
៦-វិចិកិច្ឆា, ៧-ថីនៈ, ៨-ឧទ្ធច្ចៈ ។

## កុសិតវត្ថុ "ហេតុនៃមនុស្សខ្ជិល" ៨ យ៉ាង

១-គិតថាអញនឹងត្រូវធ្វើការងារគួរសម្រាកសិន ហើយដេក ។

២-គិតថាអញធ្វើការរួចហើយ គួរឈប់ឱ្យសប្បាយ ហើយដេក។

៣-គិតថាអញនឹងត្រូវដើរផ្លូវឆ្ងាយ គួរសម្រាកសិន ហើយដេក។

៤-គិតថាអញដល់កន្លែងហើយ គួរឈប់ឱ្យសប្បាយ ហើយដេក

៥-គិតថាអញបរិភោគអាហារតិចពេក ធ្វើការមិនកើតទេ ហើយដេក ។

៦-គិតថាអញបរិភោគអាហារច្រើនពេក គួរសម្រាកអោយអាហាររលាយស្រួលស្រួលបួលសិន ហើយដេក ។

៧-គិតថាអញមិនសូវសប្បាយរកកល់ឈឺ គួរសម្រាកសិន ហើយដេក ។

៨-គិតថាអញទើបងើបពីឈឺថ្មីៗ គួរឈប់ធ្វើការងារសិន ហើយដេក ។

## អានិសង្សរបស់អ្នកចំរើនមេត្តា ៨ យ៉ាង

១-**សុខំ សុបតិ** ដេកលក់ស្រួល ។

២-**សុខំ បដិពុជ្ឈតិ** ភ្ញាក់ឡើងស្រួល ។

៣-**ន បាបកំ សុបិនំ បស្សតិ** មិនឃើញសុបិនអាក្រក់ ។

៤-**មនុស្សានំ បិរយោ ហោតិ** ជាទីស្រឡាញ់នៃមនុស្សទាំងឡាយ។

៥-**អមនុស្សានំ បិយោ ហោតិ** ទាំងជាទីស្រឡាញ់នៃអមនុស្សទាំងឡាយដែរ ។

៦-**ទេវតា រក្ខន្តិ** ទេវតាទាំងឡាយតែងរក្សា ។

៧-**នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ** ភ្លើងក្តី ថ្នាំពិសក្តី គ្រឿងសស្ត្រាវុធក្តី រមែងមិនធ្លាក់ត្រូវលើអ្នកចំរើនមេត្តានោះឡើយ

៨-**ឧត្តរិំ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ** កាលបើមិនទាន់បានត្រាស់ដឹងមគ្គផលទេ គង់ទៅកើតព្រហ្មលោកពុំខាន ។